រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៩៧

# អនុក្រឹត្យ

## អនុក្រឹត្យលេខ ០៧ អនក្រ.បក

## ស្តីពីការរៀបចំឯកសណ្ឋាន ផ្លាកសញ្ញា និងទង់ជ័យ នៃកងយោធពលខេមរភូមិន្ទ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា ។
- យោងតាមអនុក្រឹត្យលេខ ០៤ អ.ន.ក្រ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីឯកសណ្ឋាន និងផ្លាកសញ្ញា កងទ័ពជាតិកម្ពុជា ។
- យោងតាមអនុក្រឹត្យលេខ ១៨ អ.ន.ក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៤ ស្តីអំពីឯកសណ្ឋាន បច្ចេកទេស និង ទង់ជ័យ កងយោពលខេមរភូមិន្ទ ។
- យោងតាមអនុក្រឹត្យលេខ ១៩ អ.ន.ក្រ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ១៩៩៤ ស្តីពីការកែតម្រូវ និង បំពេញបន្ថែមអនុក្រឹត្យលេខ ០៤ អ.ន.ក្រ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៣ របស់ រាជរដ្ឋាភិបាលបណ្តោះអាសន្ន ។
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ ចុះថ្ងៃទី ២០ ខែ ៦ ឆ្នាំ ១៩៩៦ ។
- យោងតាមសំណើរបស់អគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ចុះថ្ងៃទី ២៥ ខែ ៥ ឆ្នាំ ១៩៩៦ ។

## សំរេច

**មាត្រា ១** : ត្រូវបានរៀបចំឯកសណ្ឋានរបស់កងយោធពលខេមរភូមិន្ទ ជាថ្មីដូចខាងក្រោម ៖

### រូបភាព ម៉ូត និង ប្រភេទឯកសណ្ឋាន

**ក–ឯកសណ្ឋានសំរាប់ថ្នាក់ឧត្តមសេនីយ៍ ជើងគោក :**

១–ឯកសណ្ឋានលេខ ១ : (អាវកុដ ស)

អាវកុដស ត្រង់ ខោពណ៌ក្រមៅ មានឆ្នូតក្រហមពីរ មួយធំខ្មៅ ជើងម្នូកពណ៌ក្រហម ។

– អាវកុដស ក ត្រង់ កាត់រាង អាវធំ គ្មានផែកខ្នង ក អាវមានប៉ាក់ ដូចធ្មេញរណា ពណ៌មាស ជុំវិញលើស្មា ទាំងសង្ខាង មានប៉ូល ហោប៉ៅបួន (ហោប៉ៅពីរខាងលើ ដេរប៉ះចំកណ្ដាល មានចាប់ផ្នត់មួយគំរបរាងស្លឹកពោធិ ហោប៉ៅពីរខាងក្រោម ដេរបង្កប់ គំរបរាងចតុកោណកែង) អាវដៃវែង កាត់ម៉ូតដៃបំពង់ លើថ្នេរបត់ចុងដៃអាវ មានប៉ានក្រណាត់ពណ៌មាស ទំហំ ៨ម.ម ឡេវអាវមានរូបព្រះសង្ខារពណ៌មាស (ឡេវធំ ពី ក មកដល់ក្រោមចំនួន ៦ ឡេវហោប៉ៅ៤ ឡេវប៉ូលស្មាទាំងសង្ខាង និងដាក់បញ្ចោត នៅចុងដៃអាវនីមួយៗ ម្ខាងបី ) ។

–ខោជើងវែងចង្កេះត គ្មានភ្លី នៅខាងក្រោយមានហោប៉ៅមួយដេរបង្កប់ គ្មានគំរប ហោមៅពីរនៅចំហៀងដេរបង្កប់តាមបណ្ដោយថ្នេរខោទាំងសង្ខាង ពីចង្កេះដល់ជើងខោមានឆ្នូតក្រហមពីរ ឆ្នូតនីមួយៗ មានទទឹង ២ ស.ម ឃ្លាតគ្នា ៥ ម.ម ។

–ម្នូកកាស្កេត ពណ៌ក្រមៅ ក្រណាត់កាំម្ទី ជើងម្នូកពណ៌ក្រហម ហាមម្នូកធ្វើអំពីកៅស៊ូរឹង ពណ៌ខ្មៅ នៅខាងលើហាមម្នូកប៉ាក់ក្បាច់ភ្ញីទេសឱន ដល់ជើងម្នូក វ័ន្តខាងមុខ និងឡេវ (រូបព្រះសង្ខារ) ពណ៌មាស ។

–ស្បែកជើង ឃ្មុប ពណ៌ខ្មៅ ធ្វើអំពីស្បែក ក ខ្ចី ។

–ស្រោមជើង ពណ៌ខ្មៅ ស្រោមដៃពណ៌ស ។

-ខ្សែរំយោល ពណ៌មាស វេញចូលគ្នា រាងសំប៉ែត ខ្សែអមបី មានម្ជុលបណ្ដោកពីរ ពណ៌មាស មានក្បាច់ភ្ញីផ្កា ។

-ខ្សែក្រវ៉ាត់ ពណ៌ត្រអ៊ី ក្បាលខ្សែក្រវ៉ាត់ ធ្វើអំពីលោហធាតុលាត ហើយពណ៌មាស (ប្រើគ្រប់ឯកសណ្ឋានទាំងអស់) ។

-ចំពោះនារី អាវមានគំរូដូចបុរស តែកាត់រាងតាមដងខ្លួននារី សំពត់ស៊ីបក្រោមជង្គង់ពណ៌ខ្មៅ មានធ្នូតក្រហមសងខាងដូចគ្នា ។

**២– ឯកសណ្ឋានធំលេខ ២ : (អាវខ័វី)**

ឯកសណ្ឋានធំលេខ២នេះ ពណ៌កាគី អាវសឺមីក្នុងមានពីរ មួយពណ៌កាគីមួយទៀតពណ៌ស ក្រវ៉ាត់ ក ពណ៌ខ្មៅ ។

– អាវកាត់រាវអាវខ័វី មានផែកខ្នងមួយ ក បើក ប៉ូលស្មាទាំងសងខាង មានហោប៉ៅបួន (ហោប៉ៅពីរ ខាងលើដេរប៉ះ ចំកណ្ដាលមានចាប់ផ្នត់មួយ គំរបរាងស្លឹកពោធិ ហោប៉ៅពីរខាងក្រោមដេរបង្កប់ មានគំរបរាងចតុកោណកែង) ដៃអាវវែង កាត់រាងដៃបំពង់ ។ ឡេវអាវ មានរូបព្រះសង្ខារ ឡេវធំបួន ឡេវហោប៉ៅបួន ឡេវតូច ប៉ូលស្មាពីរ និងឡេវបញ្ចូតនៅចុងដៃអាវម្ខាង ៣ ។

– ខោជើងវែង ពណ៌កាគី ថ្មេរបង្កប់ ចង្កេះត គ្មានភ្លី មានហោប៉ៅបួន (ហោប៉ៅពីរខាងក្រោយ ដេរបង្កប់ មានគំរបរាងស្លឹកពោធិ នៅចំហៀងពីរ ដេរបង្កប់តាមថ្មេរខោ ) ។

– មួកកាស្កេត ពណ៌កាគី ជើងមួកពណ៌ខ្មៅ ហាមមួកធ្វើអំពីជ័រឹង ពណ៌ខ្មៅ រ៉ែន្ត និង ឡេវ មួក (រូបព្រះសង្ខារ) ពណ៌មាស លើហាមមួក មានប៉ាក់ក្បាច់ភ្ញីទេសឌិន ដល់ជើងមួកទាំងសងខាង ។

– អាវសឺមី ខាងក្នុងពីរ មួយពណ៌ស មួយទៀតពណ៌ កាគី កាត់ស្រុងវែង ដាក់ក្នុងខោ មានហោប៉ៅមួយនៅខាងឆ្វេង គ្មានគំរប ដៃអាវកាត់ផែក ដាក់ឡេវបិទ ។

– ក្រវ៉ាត់ ក ពណ៌ខ្មៅ ស្រោមជើង ពណ៌ ស ។

– ស្បែកជើងឃ្ពប ពណ៌ខ្មៅ ធ្វើពីស្បែក ក ខ្ចី ។

– ខ្សែក្រវ៉ាត់ ណាណិត្រេអ៊ី ក្បាលខ្សែក្រវ៉ាត់ លោហធាតុលាត ពណ៌មាស ។

- ចំពោះនារី អាវដូចខាងលើ តែជីបចង្កេះ និង ក អាវតាមរាងដងខ្លួននារី សំពត់ហ៊្សីបក្រោម ជង្គង់ ។

-ឯកសណ្ឋាននេះ អាវ ពណ៌កាគី ខោ ពណ៌ត្រែអ៊ី ហោប៉ៅបួន ។

**៣— ឯកសណ្ឋានលេខ ៣ : (សាហារីអ៊ីយ៉ែន)**

-អាវ ដៃខ្លី ក បើក ខាងក្រោយមានផែក និង មានប៉ាចចង្កេះ ផ្នែកខាងមុខ ហោប៉ៅបួន (ពីរខាងលើដេរប៉ះ មានគំរប និងពីរខាងក្រោមដេរយោគមកក្រៅមានគំរបដូចគ្នា) ប៊ូលស្មា ទាំងសងខាង ខ្សែរូបព្រះសង្ហារ ពណ៌មាស ។

-ខោជើងវែង ពណ៌ត្រែអ៊ី (កាត់ម៉ូតដូចឯកសណ្ឋានលេខ ២ ) ។

-មួក-ស្បែកជើង និងស្រោមជើង (ដូចឯកសណ្ឋានលេខ ២) ។

-ចំពោះនារី អាវដូចបុរស តែជីបចង្កេះតាមរាងនារី ហើយសំពត់ហ៊្សីបពណ៌ត្រែអ៊ីក្រោមជង្គង់ ។

**៤— ឯកសណ្ឋានការងារ (លេខ ៤) : គំរូឯកសណ្ឋាននេះមានតែមួយសំរាប់គឺ :**

-ឯកសណ្ឋាន ការងារ អាវ ពណ៌កាគី ដៃខ្លី ហើយខោពណ៌ត្រែអ៊ី ។

-អាវដៃខ្លី ពណ៌កាគី ក ខុប ប៊ូលស្មាទាំងសងខាង កាត់ស្រុងវែងដាក់ក្នុងខោ ហោប៉ៅពីរដេរប៉ះ ចំកណ្តាល ដេរបត់ផ្នត់មួយ មានគំរបរាងស្លឹកពោធិ ខ្សែរឹមម្ចា ពណ៌កាគី ។

-ខោ ជើងវែង (ដូចឯកសណ្ឋានលេខ ៣) ពណ៌ត្រែអ៊ី ។

-មួក បោនេ ពណ៌ត្រែអ៊ី នៅស្រទាប់មួក មានចំពណ៌មាស តាមបណ្តោយ ទំហំ ៨ ម.ម ។

-ខ្សែក្រវាត់ ពណ៌ត្រែអ៊ី (ដូចខ្សែក្រវាត់ឯកសណ្ឋានលេខ១)

-ចំពោះនារី អាវដូចបុរស ខោជើងវែង កាត់ដូចបុរស តែខុសចំពោះនារី ផែកខ្សែចំហៀងឬ សំពត់ហ៊្សីប ពណ៌ត្រែអ៊ី ក្រោមជង្គង់ ។

**៥— ឯកសណ្ឋានប្រយុទ្ធ :**

–គំរូឯកសណ្ឋានប្រយុទ្ធមានតែមួយសំរាប់ អាវដៃវែង ហោប៉ៅបួន ខោជើងវែង ហោប៉ៅ៦ ជើងខោចងខ្សែ ឬដាក់ខ្សែយឺត រិតជើង ពណ៌ក្រែអ៊ីជើងគោក (ទ័ពពិសេស ស៊ើបការ ទ័ពការពារព្រំដែន និងឆ័ត្រយោង ពណ៌កាម៉ូផ្លា) ដោយឡែក ថ្នាក់ឧត្តមសេនីយ៍ ជាអគ្គិភាព អាចពាក់បានទាំងអស់ ។

–អាវដៃវែង កបើក ថ្នេរខុប ហោប៉ៅបួន ដេរយោគមកក្រៅទាំងអស់ មានគំរបរាងចតុកោណកែង ឡេវទាំងអស់ ដាក់បង្កប់ ពណ៌ក្រែអ៊ី ដៃអាវវែង កាត់ដៃបំពង់ នៅចុងដៃអាវមានក្រវ៉ាត់ និង ឡេវ លើស្មាមានប៉ូលពីរសង្ខាង ។

–ខោជើងវែងថ្នេរខុប ហោប៉ៅក្រោយពីរ ដេរបង្កប់ មានគំរបរាង ចតុកោណកែង នៅចំហៀង តាមថ្នេរខោដេរបង្កប់ មាត់ហោប៉ៅបញ្ឆិត ប៉ានជង្គង់ នៅសង្ខាងភ្លៅមានហោប៉ៅធំពីរ នៅជើងម្ខាងមួយ ផ្នែកខាងក្រៅ ហោប៉ៅដេរយោគមកក្រៅ នៅកណ្តាលហោប៉ៅ មានបត់ផ្នត់ពីរជាន់ គំរបរាងចតុកោណកែង ដាក់ឡេវពីរ ជើងខោចងខ្សែ ឬ ខ្សែយឺត ។

–មួកដែក និងមួក ហ្សិកគី ពណ៌ក្រែអ៊ី (ទ័ពពិសេស ស៊ើបការ ទ័ពការពារព្រំដែន និងឆ័ត្រយោង ពណ៌កាម៉ូផ្លា) ហើយមួកហ្សិកគី នៅលើហាមមួករបស់ឧត្តមសេនីយ៍ មានប៉ាក់ភ្ញីទេសឌិន ដូចមួក កាស្កេតដែរ ។

–ស្បែកជើងស្បែក ក វែង ពណ៌ខ្មៅ ។

–ស្រោមជើងវែង ពណ៌ក្រែអ៊ី ។

–កន្សែងរុំ (ហ៊្វូឡា) ពណ៌ក្រែអ៊ី ក្រណាត់នីឡុង ។

–ប៉េរ៉េ ពណ៌ក្រែអ៊ី ជើងគោក–ទ័ពពិសេស–ឆ័ត្រយោង ពណ៌ក្រហម ។

**១— ឯកសណ្ឋានថ្នាក់ទាហាន :**

**ខ— ឯកសណ្ឋានលេខ ១** : ដូចថ្នាក់ឧត្តមសេនីយ៍ដែរ តែមានចំណុចមួយចំនួនខុសគ្នា ដូចខាងក្រោម ÷

មួក : នៅហាមមួកក្បាច់ភ្ញីទេសឌិន នៅចុងហាមមួក ទុកចន្លោះពីជើងមួកសង្ខាងប្រវែង ៤ស.ម។

ខ្សែរំយោល : វេញចូលគ្នាបីខ្សែដែរ តែទំហំតូចជាងថ្នាក់ឧត្តមសេនីយ៍ ។

-ខោជើងវែងពណ៌ក្រមៅ ថ្នាក់វរសេនីយ៍ មានឆ្នូតពីរ ឆ្នូតនីមួយៗគំនូសទទឹង ១ ស.ម ។

២- **ឯកសណ្ឋានលេខ ២+៣** : រូបភាព-ម៉ូត-ពណ៌ដូចថ្នាក់ឧត្តមសេនីយ៍ តែខុសគ្នា នៅហាមមួកក្បាច់ភ្ញីទេសឱន ទុកចន្លោះ ពីជើងមួកសង្ខាង ៤ ស.ម ។

៣- **ឯកសណ្ឋានលេខ ៤** : (អាវការងារ) ដូចគ្នាឧត្តមសេនីយ៍ តែខុសគ្នា មួក បោននេ នៅស្រែ ទាប់មួក ថ្មេរមានចំពណ៌ក្រហម ទំហំ ៥ ម.ម ។

ឯកណ្ឋានប្រយុទ្ធ : ដូចឧត្តមសេនីយ៍ តែខុសគ្នា មួកហ៊្សកកី ក្បាច់ភ្ញីទេសឱន នៅហាមមួក ទុកចន្លោះ ៤ ស.ម ពីជើងមួក ។

**គ- ថ្នាក់អនុសេនីយ៍ :**

១- **ឯកសណ្ឋានលេខ ១** ដូចគ្នាថ្នាក់ឧត្តមសេនីយ៍ដែរ តែមានចំណុចខុសគ្នា សំរាប់សំគាល់ថ្នាក់ដូច ខាងក្រោម ÷

-មួកកាស្កេត នៅហាមគ្មានក្បាច់ភ្ញីទេសឱនទេ តែមានចំជាឆ្នូតពណ៌មាស នៅចុងហាម ប្រវែងទទឹងឆ្នូតចំនួន ៦ម.ម និងប៉ានលើ ក អាវដូចធ្មេញរណា និងប៉ាននៅដៃអាវពណ៌ប្រាក់ ។

-ខោជើងវែង ពណ៌ក្រមៅ ឆ្នូតមានតែមួយ ប្រវែងទទឹងឆ្នូត ២ ស.ម ។

២- **ឯកសណ្ឋានលេខ២+៣** : ដូចគ្នាថ្នាក់ឧត្តមសេនីយ៍ដែរ តែខុសគ្នា មួកកាស្កេត លើហាមមួកគ្មានក្បាច់ភ្ញីទេសឱនទេ មានចំឆ្នូតពណ៌មាស នៅហាមដូចមួកកាស្កេត ឯកសណ្ឋានធំលេខ១ដែរ។

៣- **ឯកសណ្ឋានការងារ** : ដូចគ្នាថ្នាក់ឧត្តមសេនីយ៍ដែរ តែមួកបោននេ ចំពណ៌ ទឹកប្រាក់ ។

៤- **ឯកសណ្ឋានប្រយុទ្ធ** : ដូចគ្នាថ្នាក់ឧត្តមសេនីយ៍ដែរតែមួយមួកហ៊្សកកី នៅហាមមួកមានចំ ឆ្នូតដូចមួកកាស្កេតដែរ ។

**ឃ –ថ្នាក់នាយទាហានរង និងពលទាហាន :**

ក្នុងលក្ខណៈ ដែលក្រសួងការពារជាតិ និងអគ្គសេនាធិការពិនិត្យឃើញថា : ត្រូវបំពេញបេសកកម្មនៅក្រៅប្រទេស ឬក្នុងពិធីការជាតិធំៗ នាយទាហានរង និងពលទាហាន អាចមានឯកសណ្ឋានធំលេខ២ ឬលេខ៣ដែរ ។ ចំពោះឯកសណ្ឋានទាំងនោះ ដូចគ្នាថ្នាក់ អនុសេនីយ៍ដែរ តែមួកកាស្កេត គ្មានក្បាច់ភ្ជីទេសឳន ឬធ្នូតអ្វីទាំងអស់ ។

ចំពោះនាយទាហានរង និងពលទាហាន មានគោលរបប តែឯកសណ្ឋានការងារ និងឯកសណ្ឋានប្រយុទ្ធតែប៉ុណ្ណោះ ។ ចំពោះឯកសណ្ឋានការងារ និងប្រយុទ្ធ ដូចគ្នាថ្នាក់អនុសេនីយ៍ដែរ តែមួកបោនេ និងមួកហ៊្សកកី គ្មានធ្នូតអ្វីទាំងអស់ ។

**មាត្រា២ :** ត្រូវរៀបចំឯកសណ្ឋាន កងនាវាចរភូមិន្ទ និងអាកាសចរភូមិន្ទ ដូចខាងក្រោមនេះ ÷

**ក– ឯកសណ្ឋានកងនាវាចរភូមិន្ទកម្ពុជា :**

ឯកសណ្ឋានកងនាវាចរភូមិន្ទកម្ពុជា គ្រប់ឯកសណ្ឋាន និងគ្រប់ថ្នាក់ នាយទាហាន នាយទាហានរង និងពលទាហាន ដូចទ័ពជើងគោក តែខុសគ្នាពណ៌តែប៉ុណ្ណោះ ។ ពណ៌ឯកសណ្ឋាន កងនាវាចរភូមិន្ទ ត្រូវបានកំណត់ដូចខាងក្រោម ÷

–ឯកសណ្ឋានលេខ ១–២–៣–៤ (អាវកុងស អាវរ៉ាបី សាហារីយ៉ែន និងការងារ) មួកគ្រប់ប្រភេទ ស្បែកជើង និងស្រោមជើង ពណ៌សទាំងអស់ ។ ចំពោះអាវសឺមីក្នុង របស់ឯកសណ្ឋានលេខ ២ មានតែមួយ ពណ៌សតែប៉ុណ្ណោះ ។ ដោយឡែក ឯកសណ្ឋានការងារមាន ២សំរាប់ (១សំរាប់ពណ៌ស) ខ្សែក្រវ៉ាត់ ពណ៌ស ក្បាលខ្សែក្រវ៉ាត់លាត ពណ៌មាស ។ ចំពោះនាយទាហានរង និងពលទាហាន អាវការងារ ពណ៌ស ក អាវទំលាក់មកក្រោមរាងជាកន្សែងវែង ប្រវែង ២៥ស.ម ជុំវិញ ក អាវនេះមានឆ្នូតបីពណ៌ខៀវ ឆ្នូតនីមួយៗមានទំហំ ៨ម.ម ។ ហើយពាក់មួក ម៉ាតឡូពណ៌ស ជើងមួក ពណ៌ខៀវ លើជើងមួកសរសេរអក្សរពណ៌សថា

(កងនាវាចរភូមិន្ទ កម្ពុជា) កំពស់អក្សរ ១៥ ម.ម។ ជើងម្លូកខាងក្រោយផែក មានខ្សែពីរសំរាប់ ចងកន្ទុយខ្សែមានរាងកន្ទុយត្រី ។

–ឯកសណ្ឋានប្រយុទ្ធដូចទំពជើងគោក តែប៉េរ៉េ ពណ៌ខៀវ ទឹកសមុទ្រហើយ កន្សែងរុំក (ហ៊្វូឡា) ពណ៌ខៀវទឹកសមុទ្រ (ខៀវទឹកប៊ិច) ។

**ខ– ឯកសណ្ឋានអាកាសចរភូមិន្ទកម្ពុជា :**

–គ្រប់ប្រភេទនៃឯកសណ្ឋាន និងគ្រប់បណ្ដាថ្នាក់នាយទាហាន នាយទាហានរង និងពលទាហាន មានឯកសណ្ឋានដូចគ្នាជើងគោក តែឯកសណ្ឋានអាកាសចរ ភូមិន្ទកម្ពុជា ត្រូវបានកំណត់ពណ៌ដូចខាង ក្រោម ÷

–**ឯកសណ្ឋានលេខ ១ :** អាវកុដស ពណ៌ស ខោពណ៌ខៀវក្រមៅ និងម្លូកកាស្កេត ពណ៌ខៀវក្រមៅ ជើងម្លូកពណ៌ក្រហម ។

–**ឯកសណ្ឋានលេខ២–៣–៤ :** ពណ៌ខៀវក្រមៅ ស្បែកជើងពណ៌ខ្មៅ ដូចទំពជើងគោក ដោយឡែកអាវ សឺមីក្នុងរបស់ឯកសណ្ឋានធំលេខ ២ កាត់ដូចជើងគោកតែមួយ ពណ៌ផ្ទៃមេឃ មួយទៀតពណ៌ស ។ ហើយ ឯកសណ្ឋានការងារ មានមួយសំរាប់ អាវពណ៌ខៀវផ្ទៃមេឃ ខោពណ៌ខៀវក្រម៉ៅ ម្លូកបោននេពណ៌ខៀវក្រមៅ កាត់ដូចទំពជើងគោក និងខ្សែក្រវ៉ាត់តូចពណ៌ខៀវទឹកប៊ិច ក្បាលលាត ពណ៌មាស ។

–**ឯកសណ្ឋានប្រយុទ្ធ :** ដូចទ័ពជើងគោក តែប៉េរ៉េ និងកន្សែងរុំក ពណ៌ខៀវ (ខៀវផ្ទៃមេឃ) ។

**មាត្រា ៣ :** ត្រូវបានរៀបចំ ឯកសណ្ឋានត្រៃទ័ព និងកងកិត្តិយសដូចខាងក្រោម ÷

**ក– ឯកសណ្ឋានត្រៃទ័ព :** ឯកសណ្ឋានត្រៃទ័ពមានពីរសំរាប់ មួយពណ៌ស មួយទៀតពណ៌កាគី ម៉ូតរូបភាពឯកសណ្ឋាន និង ម្លូកកាស្កេត ដូចឯកសណ្ឋានលេខ ២ តែម្លូកកាស្កេត ធ្វើតាមឋានៈដូចទ័ពជើងគោក ស្បែកជើងស្បែកកវែង ពណ៌ខ្មៅ ខ្សែក្រវ៉ាត់ធំពណ៌ខ្មៅ ក្រវ៉ាត់ពី លើអាវ អាវសឺមីក្នុង ពណ៌កាគីមួយ ពណ៌សមួយ ខ្សែរំយោល ពណ៌មាស និងកន្សែងរុំក ពណ៌លឿងស្រាមដៃពណ៌ស ។

**ខ— ឯកសណ្ឋានកងកិត្តិយស :**

**១— ឯកសណ្ឋាន មេបញ្ជាការ កងកិត្តិយស និងអ្នកកាន់ទង់ :** ត្រូវពាក់ឯកសណ្ឋានលេខ២ របស់ទ័ពជើងគោក តាមឋានន្តរសក្តិជាក់ស្តែង ។ ចំពោះមេបញ្ជាការកងកិត្តិយស តាមបណ្តាផែនជើងគោក–នាវាចរ–អាកាសចរ ត្រូវបានពាក់ឯកសណ្ឋានធំលេខ២ តាមឋានន្តរសក្តិជាក់ស្តែង និង តាមប្រភេទទ័ព ។

**២— ឯកសណ្ឋានកងកិត្តិយសជើងគោក :** ឯកសណ្ឋានមានមួយសំរាប់ ពណ៌កាគី ដូចត្រៃទ័ព តែខុសត្រង់កងកិត្តិយសជើងគោក ពាក់មួកស៊ូកាស ពណ៌ខ្មៅ កន្សែងរុំក ពណ៌លឿង ។

**៣— ឯកសណ្ឋានកងកិត្តិយសនាវាចរ :** ឯកសណ្ឋានពណ៌ស មួកស៊ូកាស ពណ៌ស និងកន្សែងរុំកពណ៌ស(កាត់ម៉ូតឯកសណ្ឋានលេខ២ កងនាវាចរភូមិន្ទកម្ពុជា)។

**៤— ឯកសណ្ឋានកងកិត្តិយសអាកាសចរ :** ឯកសណ្ឋានពណ៌ខៀវក្រមៅ មួកស៊ូ កាសពណ៌ខៀវ កន្សែងរុំក ពណ៌ផ្ទៃមេឃ កាត់ដូចឯកសណ្ឋានលេខ ២ កងអាកាសចរភូមិន្ទកម្ពុជា ។

**៥— ឯកសណ្ឋានកងកិត្តិយសជាន់ :** ពាក់ឯកសណ្ឋានលេខ ១ ថ្នាក់អនុសេនីយ៍ ប្រើដាវមានស្រោម ពណ៌ស ខ្សែរយោលដាវពណ៌មាស ដងដាវឆ្លាក់រូបព្រហ្ម មុខបួន ផ្ទៃដាវពណ៌ទឹកប្រាក់ ចង្កឹនិងដង ដាវក្បាច់ពណ៌មាស ។

មាត្រា ៤ : ត្រូវបានរៀបចំឯកសណ្ឋានសំរាប់បំរើការរបស់ទ័ពបច្ចេកទេសជំនាញ ដូចខាងក្រោម ÷

**ក— ឯកសណ្ឋានបច្ចេកទេសទ័ពរថក្រោះ រថពាសដែក :**

ឯកសណ្ឋានពណ៌ខ្មៅ អាវដៃវែង ខោជើងវែង ថ្ងៃរខុប ឡេវបង្កប់ កាត់ម៉ូតឯកសណ្ឋានប្រយុទ្ធទ័ព ជើងគោក ប៉េរ៉េ ពណ៌ខ្មៅ ស្បែកជើងស្បែកកវែង និងស្រោមជើង ពណ៌ខ្មៅ ។

**២– ឯកសណ្ឋានបច្ចេកទេស គ្រឿងយន្តវិស្វកម្ម និង អ្នកបំរើការរោងជាងជួស ជុលឬសិប្បកម្ម យោធា :**

–ឯកសណ្ឋានពណ៌ខៀវ អាវដៃវែង ខោជើងវែង ចង្កេះត ជីបភ្ជិ ហោប៉ៅក្រោយពីរ ដេរបង្កប់ គំរបរាងស្លឹកពោធិ និងហោប៉ៅចំហៀងពីរ ដេរបង្កប់តាមថ្នេរខោ ខ្សែរបង្កប់ ថ្នេរឌុប ពាក់មួកហ៊្សកកីពណ៌ខៀវ ។

**៣– ឯកសណ្ឋានបច្ចេកទេសពេទ្យយោធា :**

–ឯកសណ្ឋាន ពណ៌ស អាវដៃខ្លី កបើក ហោប៉ៅបី (មួយនៅលើឆ្វេងគ្មានគំរប និងពីរនៅខាងក្រោម ធំគ្មានគំរប) កាត់ស្រុងវែងដល់ជង្គង់ ខោជើងវែង ពណ៌ស ចង្កេះរឹត មានហោប៉ៅក្រោយ មួយគ្មានគំរប ។

**៤– ឯកសណ្ឋានកងជីវពល :**

–ឯកសណ្ឋានកងជីវពលគ្រប់ប្រភេទ មាន១សំរាប់ អាវដៃវែង ពណ៌ខៀវទឹកប៊ិច កបើក ហោប៉ៅលើពីរដេរប៉ះ មានគំរបដូចស្លឹកពោធិ ដៃអាវវែងខ្សែរបង្កប់ ប៊ូលស្មាសង្ខាងកាត់ស្រុងវែង ដាក់ក្នុងខោ ។ ខោជើងវែងមានប៉ានជង្គង់ ពណ៌ត្រអ៊ី (កាត់ម៉ូត ខោការងារទំពជើងគោក) មួកហាមធំពណ៌ទឹកប៊ិច ស្បែកជើង សំពត់ និងស្រោមជើងពណ៌ត្រអ៊ី និងខ្សែក្រវាត់ដូចទំពជើងគោក ។

**៦– ឯកសណ្ឋានបច្ចេកទេសនាវាចរភូមិន្ទកម្ពុជា :**

–ឯសណ្ឋានបច្ចេកទេស កងនាវាចរខេមរភូមិន្ទ សំរាប់ក្រុម នាវិកនៅលើកប៉ាល់ម៉ារីន និងរោងជួសជុល ពេលធ្វើការងាររបច្ចេកទេស ដូចជាថែទាំបច្ចេកទេស និងជួសជុលមិនបានពាក់ចេញ ក្រៅកងឯកភាពឡើយ ។

**រូបភាព និង ម៉ូត** : ឯកសណ្ឋានក្រណាត់កាគី ពណ៌ទឹកប៊ិច អាវដៃវែង ខោជើងខ្លី និង វែង ។

–អាវកបើក ថ្នេរឌុប អាវដៃបំពុង មានក្រវាត់ខ្សែរ ហោប៉ៅពីរ ដេរយោគំរបរាងចតុកោណ កែង ខ្សែរបង្កប់ ក្រាត់ចង្កេះ ទំហំ ៦ ស.ម ។

-ខោជើងខ្លីលើផង្គង់ ចង្កេះត ដឹបភ្លី ហោប៉ៅក្រោយពីរ ដេរបង្គប់ តំបរាង ស្លឹកពោធិ ហោប៉ៅ ចំហៀងពីរ បង្កប់តាមថ្នេរខោ ។

-ខោជើងវែង កាត់ដូចខោជើងខ្លី តែខុសត្រង់មួយជើងវែង មួយជើងខ្លី ។

-ខ្សែក្រវាត់ពណ៌ទឹកប៊ិច ក្បាលខ្សែក្រវាត់ ពណ៌មាសលាត ។

-មួកហ៊្វូកគី ពណ៌ខៀវ ស្បែកជើង ប៊ំពង់កៅស៊ូ កវែង ពណ៌ខ្មៅ ស្រោមជើងខ្មៅ ស្រោមដៃ ពណ៌ខ្មៅ ។

**គ- ឯកសណ្ឋានបច្ចេកទេស អាកាសចរភូមិន្ទកម្ពុជា :**

-ឯកសណ្ឋានបច្ចេកទេស កងអាកាសចរភូមិន្ទ សំរាប់ក្រុមបច្ចេកទេសយន្តហោះ និង អ្នកឯកទេស ជួសជុលយន្តហោះគ្រប់ប្រភេទ ពេលធ្វើការងារបច្ចេកទេស ដូចជាថែទាំ ធានាបច្ចេកទេស និងជួសជុលមិនបានពាក់ពេញក្រៅអង្គភាពឡើយ ។

-**របភាព និង ម៉ូត :** ឯកសណ្ឋានទាំងអស់ដូចឯកសណ្ឋានបច្ចេកទេសកងនាវាខេមរភូមិន្ទ តែគ្មាន ខោ ជើងខ្លីទេ ។

-ចំពោះឯកសណ្ឋានអ្នកបើកយន្តហោះគ្រប់ប្រភេទ ត្រូវរៀបចំតាមប្រភេទយន្តហោះ និងតាមលក្ខណៈបច្ចេកទេសជាក់ស្តែង ។

**មាត្រា៥ :** ត្រូវរៀបចំផ្លាកសញ្ញា សំរាប់ជាទូទៅក្នុងកងយោធពលខេមរភូមិន្ទដូចខាងក្រោម ÷

**ក- រូបព្រះសង្ហារ :**

-រូបព្រះសង្ហារយកតាមសម័យសង្គមរាស្ត្រនិយម ធ្វើពីលោហធាតុ ពណ៌មាស នៅលើវិន្ទព្រះសង្ហារមានសរសេរអក្សរ **ព្រះចៅក្រុងកម្ពុជា** ។ សំរាប់ពាក់លើមួកកាស្កេត និង មួកស៊ូកាស ទំហំ កំពស់ ៧.៨ ស.ម ទទឹង ៦.៥ ស.ម ។ សំរាប់លើមួកហ៊្វូកគី ចោននេ មួកហាមធំ និងប៉េរ៉េ ទំហំ កំពស់ ៥ស.ម និងទទឹង ៤ស.ម ។

**ខ- ផ្លាកសញ្ញាកងយោធពលខេមរភូមិន្ទ :**

១- ផ្លាកសញ្ញាពាក់នៅលើដៃអាវស្តាំ ចុះពីថ្នេរស្មា ៥ស.ម មានរាងមូល បន្ទាត់ផ្ចិត ៨ស.ម ស្រទាប់ខាងក្រៅ ពណ៌ស ទទឹងស្រទាប់នេះ ៣ម.ម ផ្ទៃខាងលើ

១/៤ នៃរង្វង់ពណ៌ខៀវ ហើយសរសេរអក្សរ ពណ៌ស ផ្នែកខាងលើកោងតាមរង្វង់ថា (**ព្រះរាជាណាចក្រកម្ពុជា**) កំពស់អក្សរ ៥ស.ម ផ្នែកកណ្តាល ១/២ នៃរង្វង់ពណ៌ក្រហម ហើយមានប្រាសាទអង្គរវត្ត កំពូលបី ពណ៌ស កំពស់ប្រាសាទ ២.៥ ស.ម ផ្នែកខាងក្រោម ១/៤ នៃរង្វង់ពណ៌ខៀវ សរសេរអក្សរកាត់ពណ៌ខៀវថា (**ខ.ភ.ម**) កំពស់អក្សរ ៧ ស.ម។ ចំពោះការផលិតធ្វើពីក្រណាត់ អាចបោះពុម្ព ឬ ប៉ាក់ ។

២– ផ្លាកសញ្ញារូបហនុមាន ធ្វើរាងជាមេដៃ ពាក់រាងជាមេដៃ ពាក់បន្តោងនៅខ្សែហោប៉ៅអាវស្តាំ ។ ផ្លាកសញ្ញាធ្វើអំពីលោហធាតុ ផ្នែកខាងលើមានមកុដពណ៌មាស សង្វាងមានរំយោលម្ខាង ៣ ពណ៌មាស (តំណាងអោយទង់ជាតិ) ផ្នែកកណ្តាល ពណ៌ខៀវទឹកប៊ិច លើផ្នែកកណ្តាល មានរូបហនុមានកាន់ព្រះខ័ន្ធកំពុងសំដែងរិទ្ធពណ៌ស្វាទុំ នៅផ្នែកខាងក្រោមមានជើងពានរាង ដូចស្នែងក្របីផ្នែកពណ៌ក្រហម រឹមជុំវិញពណ៌មាស នៅលើផ្នែនោះ សរសេរអក្សរកាត់ថា (ខ.ភ.ម) ពណ៌ស ។

**ខ្នាត** : កំពស់រូបភាព ៦០ម.ម ទទឹង ៤៥ ស.ម ។

កំពស់មកុដ ២៧ម.ម បាតក្រោមមកុដ ៣៤ ម.ម ។

–ផ្នែកពណ៌ខៀវកណ្តាលកំពស់ ៣២ ម.ម ទទឹង៣០ ម.ម ហនុមានកំពស់ ២៤ម.ម ទទឹង ២៤ម.ម។

–រំយោលសង្វាង ប្រវែងទី ១ = ១៦ម.ម ទី២= ១៤ម.ម ទី៣ = ១២ ម.ម ។

–ជើងពានផ្នែកខាងក្រោមមានរាងដូចស្នែងក្របី បណ្តោយប្រវែង ៣៤ម.ម ទទឹង ៦ម.ម អក្សរកំពស់ ៤ម.ម ។

–សញ្ញាដាក់លើស្បែក សំរាប់ពាក់ពីខ្សែរ ហោប៉ៅស្តាំ ប្រវែងស្បែកពីលើមកក្រោម ១០ ស.ម ។

**គ- ផ្លាកឈ្មោះរបស់នាយទាហាន នាយទាហានរង និង ពលទាហាន នៃកងយោធពលខេមរភូមិន្ទ :**

១- ផ្លាកឈ្មោះធ្វើពីជ័រផ្លាស្ទិច ផ្ទៃពណ៌ខ្មៅ គូសបន្ទាត់ជុំវិញពណ៌មាស បណ្តោយផ្លាក ១០ ស.ម ទទឹង ២ស.ម កំពស់អក្សរ ៧ម.ម ពណ៌មាស សរសេរជាអក្សរខ្មែរ ។ ហើយអាចធ្វើផ្លាកឈ្មោះដែលមានផ្ទៃ និងទំហំដូចគ្នាជាអក្សរឡាតាំង មួយទៀតមិនបានសរសេរ ក្នុងផ្លាកតែមួយអក្សរខ្មែរផង និងអក្សរឡាតាំងផងឡើយ ឬ ដាក់ផ្លាកសញ្ញាផ្សេងៗទៀតលើ ផ្លាកឈ្មោះទេ ។ នៅខាងដើម នាមត្រកូលនិងនាមខ្លួន ត្រូវសរសេរកាត់ពី ឋានន្តរសក្តិរបស់យោធិនម្នាក់ៗ គឺយកតែអក្សរទី១ នៃឈ្មោះសក្តិ ចំពោះអក្សរឡាតាំងភាសាអង់គ្លេស ឬបារាំង ត្រូវយកតាមការសរសេរកាត់ ដែលគេបានកំណត់ជាទូទៅ នៃអន្តរជាតិ ។ ចំពោះឯកសណ្ឋានប្រយុទ្ធ ដាក់ផ្លាកឈ្មោះធ្វើពីក្រណាត់ ពណ៌គ្រែអ៊ី ស្មើហោប៉ៅ ទទឹង២ស.ម សរសេរអក្សរពណ៌ខ្មៅដេរភ្ជាប់អាវលើហោប៉ៅស្តាំ កំពស់អក្សរ និងកន្លែងពាក់ដូចផ្លាកខាងលើ។

**មាត្រា ៦ :** ត្រូវបានរៀបចំផ្លាកសញ្ញាបណ្ណថ្នាក់ និងបណ្ណទ័ពជំនាញនៃប្រភេទទ័ពដូចខាងក្រោមនេះ ÷

១- ផ្លាកសញ្ញាសំរាប់ថ្នាក់ដឹកនាំ អគ្គមេបញ្ជាការ ថ្នាក់ដឹកនាំក្រសួង និងអគ្គសេនាធិការដែលមាន សិទ្ធិបញ្ជាកងយោធពលខេមរភូមិន្ទ ទាំងបីប្រភេទទ័ព ។

**រូបភាព :** នៅផ្នែកខាងលើមានមកុដ តំណាងអោយប្រជាជាតិខ្មែរ និងផ្នែកខាងក្រោម មានលំពែង ស្នាបសត្វ និងយុថ្កា តំណាងអោយបីប្រភេទទ័ពសញ្ញា មានរាងដូចស្នែងក្របី ផលិតពីលោហធាតុ ពណ៌មាសអាចប៉ាក់ជាក្រណាត់ពណ៌ខ្មៅ រូបពណ៌មាស តែនៅលើឯកសណ្ឋានប្រយុទ្ធមួយប៉ុណ្ណោះ។

**ខ្នាត :** កំពស់រូបភាព ៤ស.ម ទទឹង ៣ស.ម ។

-កំពស់មកុដ ១.៨ស.ម បាតក្រោមមកុដ ១.៣ស.ម ។

-កំពស់យុថ្កា ១.៦ស.ម ចុងផ្លែយុថ្កា ពីម្ខាងទៅម្ខាង ២ ស.ម ។

-កំពស់លំពែង ដោយគិតពីដងយុថ្កា ០.៦ស.ម ។

-ស្លាបសត្វរាងដូចស្នែងក្របី ម្ខាងៗមានស្លាបបីជាន់ (ជាន់ទី១ = ១១ ស្លាប ទី២ = ៩ស្លាប ទី៣ = ៧ ស្លាប) កំពស់ ២៤ ម.ម ពីចុងម្ខាង ទៅម្ខាងទៀត ៣៥ម.ម ។

-សំរាប់ពាក់នៅលើ កអាវ នៃឯកសណ្ឋានយោធា (ចំពោះការណែនាំពាក់នៅមាត្រាខាងក្រោយ ) ។

២– **សំរាប់ផ្លាក់ឧត្តមសេនីយ៍ :**

**រូបភាព** : នៅចំកណ្ដាលមានរូបយុថ្កាបញ្ឈរ និងមានលំពែងមានផ្លែបីបញ្ឈរទៅលើ ខាងក្រោមយុថ្កា នៅសង្ខាងមានស្លាបសត្វ មានរាងដូចស្នែងក្របី ។ ផលិតពីលោហធាតុ ពណ៌មាស កំរាស់១.៥០ ម.ម ពាក់នៅលើអាវទាំងសង្ខាង ឯកសណ្ឋានប្រយុទ្ធប៉ាក់ជាក់ កអាវ ពណ៌មាស ។

**ខ្នាត** : កំពស់រូបភាព ៣៦ម.ម ទទឹង ៣៥ម.ម ។

-កំពស់យុថ្កា ២៥ម.ម ចុងផ្លែយុថ្កា ពីម្ខាងទៅម្ខាង ២២ម.ម ផ្លែព្រះខ័នគិតពីចុងយុថ្កាខាងទៅ ១១ ម.ម ។ ស្លាបសត្វរាងដូចស្នែងក្របី ម្ខាងៗមានស្លាបបីជាន់ ជាន់ទី១ មាន១១ ស្លាប ជាន់ទី ២ មាន៩ស្លាប ជាន់ទី៣ មាន៧ស្លាប កំពស់២៤ម.ម ពីចុងស្លាបខាងលើ ម្ខាងទៅម្ខាង ៣៥ម.ម។

៣– សញ្ញាកងថ្មើរជើង :

**រូបភាព** : មានកាំភ្លើងពីសម័យដើម ២ខ្វែងគ្នា រាងសញ្ញាលេខគុណ កាំភ្លើងខាងស្ដាំ ខ្វែងលើកាំភ្លើងខាងឆ្វេង ផលិតពីលោហធាតុ ពណ៌មាស កំរាស់ ១.៥០ម.ម ឯកសណ្ឋានប្រយុទ្ធ ប៉ាក់ជាក់ ក អាវ ពណ៌មាស ។

**ខ្នាត** : ប្រវែងកាំភ្លើងនីមួយៗ ៣៥ម.ម ស្មាយកាំភ្លើងនីមួយៗប្រវែង ៨ម.ម ចុងកាំភ្លើង ១.៥០ ម.ម ចំណុចខ្វែងគ្នាចំពាក់កណ្ដាល មុំខាងលើ ១២៥អង្សារ មុំចំហៀង ៥៥ អង្សារ ។

-សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានថ្មើរជើង ពាក់នៅលើកអាវយោធា ។

**៤– សញ្ញាកងនាវាចរខេមរភូមិន្ទ :**

**រូបភាព** : មានរូបសញ្ញាយុថ្កាពីរខ្វែងគ្នា ចំណុចប្រសព្វជាមុំកែងនៅពាក់កណ្តាល រំលេចដោយខ្សែពួរពីរព័ទ្ធជុំវិញ យុថ្កានីមួយៗ ផលិតពីលោហធាតុពណ៌មាស មានកំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធ ចាក់ជាក់ កអាវពណ៌មាស ។

**ខ្នាត** : ទំហំរូបភាព សញ្ញាទទឹង ២៩ម.ម កំពស់ ២៦ម.ម ។

–ប្រវែងយុថ្កានីមួយៗ ៣៤ម.ម ។

–ទំហំដងយុថ្កាប្រវែងទទឹង ២ម.ម ។

–រង្វង់កងដងយុថ្កាដែលមានបន្ទាត់ផ្ចិតខាងក្រៅ ៤ម.ម និងបន្ទាត់ផ្ចិតខាងក្នុង ២ម.ម ។

–ទំហំខ្សែ ២ម.ម ។

–ប្រវែងដែកខ្វែងយុថ្កា ១០ម.ម ទំហំ ១.៥ម.ម ឃ្លាតពីកងយុថ្កា ៣ម.ម ។

–ចុងផ្លែយុថ្កា ម្ខាងទៅម្ខាងប្រវែង ១៦ម.ម ។

–សំរាប់នាយទាហាន នាយទាហានរង និងពលទាហាន កងនាវាចរខេមរភូមិន្ទ ពាក់លើ កអាវ យោធា ។

**៥– សញ្ញាកងនាវាចរខេមរភូមិន្ទ សំរាប់ដាក់លើមួកសក្តិ :**

**រូបភាព** : រូបយុថ្កាពីរ ប្រសព្វជាមុំកែង នៅចំកណ្តាលដង ដែលមានព័ទ្ធជុំវិញដោយខ្សែ ។ ហើយមានមកុដនៅលើ យុថ្កាទាំងពីរ ផលិតពីលោហធាតុពណ៌មាស កំរាស់ ១.៥ ម.ម ។

**ខ្នាត** : កំពស់រូបភាព ៣៤ម.ម ទទឹង ២០ម.ម ។

–មកុដមានបាតទទឹងខាងក្រោម ១៦ម.ម កំពស់មកុដ ២៨ម.ម ។

–យុថ្កានីមួយៗប្រវែង ២៧ម.ម ទទឹង ១៣ម.ម នៅចុងដងយុថ្កាមានរង្វង់មូលមានបន្ទាត់ផ្ចិត ខាងក្រៅ ៣ម.ម ខាងក្នុង ១.៥ម.ម ។

–នៅលើដងយុថ្កា មានដែកកាត់ទទឹងប្រវែង ០៧ម.ម ទំហំ ០១ម.ម ឃ្លាតពីរង្វង់ប្រវែង ០៥ម.ម។

-ទំហំខ្សែបូរ វ៉ៃយុត្ថា ០១ម.ម ។

-ផ្ទៃយុត្ថានីមួយៗ ពីចុងម្ខាងទៅចុងម្ខាង ១៤ ម.ម ។

-សំរាប់ដាក់នៅលើហ្មុងសក្តិគ្រប់ប្រភេទរបស់កងនាវាចរខេមរភូមិន្ទ លើកលែងតែសក្តិប្រយុទ្ធ ។

**៦- សញ្ញាគងអាកាសចរខេមរភូមិន្ទដាក់លើមោងឆ័ត្រស្ទាំ :**

**រូបភាព** : រូបស្លាបសត្វ នៅពីលើរូបស្លាបសត្វ ចំពាក់កណ្តាលមានរូបម្កុដ ធ្វើពីលោហធាតុ ពណ៌មាស កំរាស់ ១ម.ម ចំពោះឯកសណ្ឋានប្រយុទ្ធ ចាក់ដាក់ជាប់អាវពណ៌មាស ។

**ខ្នាត** : រូបភាពមានកំរាស់ ៣២ ម.ម ទទឹង ៥៥ម.ម ។

-មានបាតក្រោមប្រវែង១៤ម.ម កំពស់ គិតពីរូបសែងរបស់ម្កុដដល់ចុងខាងលើមានប្រវែង ២៥ម.ម។

- ស្លាបសត្វម្ខាងៗមានពីរជាន់ ។ ជាន់ទីមួយមានស្លាប៩ ទីពីរមានស្លាប៧ ។

- សំរាប់នាយទាហាន នាយទាហានរង និងពលទាហាន អាកាសចរភូមិន្ទពាក់លើហោប៉ៅស្តាំ ហើយខាងលើផ្លាកឈ្មោះទៀត ។

**៧- សញ្ញាអាកាសចរខេមរភូមិន្ទដាក់លើហ្មុងសក្តិ :**

**រូបភាព** : មានរូបស្លាបសត្វ និងរូបម្កុដដាក់ពីលើចំកណ្តាល ផលិតពីលោហធាតុពណ៌មាស កំរាស់១ម.ម ។

**ខ្នាត** : រូបភាពមានកំពស់ ២៥ម.ម ទទឹង ៣០ម.ម ។

-រូបម្កុដមានបាតក្រោមប្រវែង ១០ម.ម កំពស់ពីរូបសែងម្កុដទៅលើប្រវែង ២១ម.ម ។

-ស្លាបសត្វនីមួយៗ មានមួយជាន់ មានស្លាបចំនួន ៥ ។

-រូបភាពនេះដាក់លើហ្មុងសក្តិប៉ប្រភេទរបស់កងអាកាសចរខេមរភូមិន្ទ លើកលែងតែសក្តិ ប្រយុទ្ធ ។

**៨– សញ្ញាអាកាសចរខេមរភូមិន្ទ ពាក់លើ កអាវ :**

**រូបភាព** : (ដូចរូបអាកាសចរខាងលើ) ផលិតពីលោហធាតុ ពណ៌មាស កំរាស់ ១ម.ម ឯកសណ្ឋានប្រយុទ្ធ និងឯកសណ្ឋានបច្ចេកទេស អ្នកបើកបរយន្តហោះ ចាក់ជាប់ កអាវ ពណ៌មាស។

**ខ្នាត** : រូបភាពមានកំពស់ ៣០ម.ម ទទឹង ៣៥ម.ម ។
នៅចំកណ្តាលស្លាបសត្វ ប្រវែងបណ្តោយ ១៦ម.ម កំពស់ ១០ម.ម ស្លាបមានពីរជាន់ មួយជាន់ៗ មាន ៦ ស្លាប ។
–សំរាប់នាយទាហាន នាយទាហានរង និង ពលទាហាន កងអាកាសចរខេមរភូមិន្ទ ពាក់កអាវយោធា លើលែងតែកងការពារដែនអាកាស និងកងដឹកជញ្ជូនអាកាសចរ ចេញប្ញជំនាញមួយចំនួនទៀត ។

**៩– សញ្ញាអាកាសយានិកសំគាល់សញ្ញាប័ត្របោះហើរ និងសំរាប់ពាក់លើផ្ទៃហោះជើងឆ្វេង :**

**៩–១ អ្នកបើកបរយន្តហោះ :**

**រូបភាព** :មានរូបសត្វហង្សកំពុងត្រដាងស្លាបឈរក្នុងរង្វង់មូល មានក្បាច់ផ្កាភ្ញីពីសម័យអង្គរ ចំនួនបីជាន់ ខាងក្រោមមានចងខ្សែបូ រូបភាព ពណ៌មាស ផលិតពីលោហធាតុ ពណ៌មាស ។

**ខ្នាត** :កំពស់សត្វហង្សប្រវែង ២៨ម.ម ទទឹងពីចុងស្លាប ម្ខាងទៅម្ខាងប្រវែង ៦០ម.ម ហើយរូបហង្ស ឈរត្រដាងស្លាប កំពុងប្រុងប្រៀបហើរ ។
–រង្វង់ក្បាច់ផ្កាភ្ញី ខាងក្នុងមានបន្ទាត់ផ្ចិតប្រវែង ៣០ម.ម ខាងក្រៅមានបន្ទាត់ផ្ចិត ៤០ម.ម ។
–រូបភាពនេះសំរាប់ដាក់លើសញ្ញាប័ត្ររបស់អាកាសយានិក អ្នកបើកបរយន្តហោះ និង ដាក់លើផ្ទៃហៅប៉ៅឆ្វេង អ្នកបើកយន្តហោះ គ្រប់ប្រភេទ ។

**៩—២ សញ្ញសំគាល់សញ្ញាប័ត្រហោះហើរយន្តការី និង សំរាប់ពាក់លើផ្ទៃហោរប៉ៅឆ្វេង :**

**រូបភាព** : ខ្នាត និងពណ៌ដូចរូបភាពទី១ តែខុសគ្នា នៅជើងសត្វហង្សមានរូបសញ្ញាគ្រឿងចក្រ មានបន្ទាត់ផ្ចិតខាងក្រៅប្រវែង ៨ម.ម ខាងក្នុង ៣ម.ម ។

– សំរាប់ដាក់លើសញ្ញាប័ត្រហោះហើររបស់យន្តការី និងសំរាប់ពាក់លើផ្ទៃហោប៉ៅឆ្វេង ។

**៩—៣— សញ្ញសំគាល់សញ្ញាប័ត្រហោះហើរ បុគ្គលិកបង្ហាញនាញផ្លូវ និង ពាក់លើផ្ទៃហោរប៉ៅឆ្វេង**

–រូបភាព ខ្នាត និងពណ៌ ដូចរូបភាពខាងលើ តែខុសគ្នានៅលើជើងសត្វហង្ស មានរូបសញ្ញា ផែនដី មានបន្ទាត់ផ្ចិត ៨ម.ម ។

–សំរាប់ដាក់លើសញ្ញាប័ត្រហោះហើររបស់បុគ្គលិកបង្ហាញផ្លូវ និង សំរាប់ដាក់លើផ្ទៃហោប៉ៅឆ្វេង ។

**៩—៤ សញ្ញាសំគាល់សញ្ញាប័ត្រហោះហើរបុគ្គលិកវិទ្យុទាក់ទង និង ពាក់លើផ្ទៃហោរប៉ៅឆ្វេង ៖**

—**រូបភាព ខ្នាត និងពណ៌** : ដូចរូបភាពខាងលើ តែខុសគ្នា នៅជើងសត្វហង្ស មានរូបសញ្ញាផែនដី និង សញ្ញារលកធាតុអាកាសនៅចំកណ្តាល ។ បន្ទាត់ផ្ចិតរង្វង់រូបផែនដីប្រវែង ៨ម.ម ។

–ដាក់លើសញ្ញាប័ត្រហោះហើររបស់បុគ្គលិកវិទ្យុទាក់ទង និងបង្ហាញផ្លូវ និង សំរាប់ពាក់លើផ្ទៃ ហោប៉ៅឆ្វេង ។

**១០—សញ្ញាកងចលនុត្តម្ភ និង សំភារៈ :**

**រូបភាព** : មានរូបក្លមនៅខាងលើ មានអណ្តាតភ្លើងនៅលើក្លម មានគូររង្វង់រាងពងក្រពើ ផលិតពីលោហធាតុ ពណ៌មាស កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធប៉ាក់ដាក់ កអាវ ពណ៌មាស ។

**ខ្នាត** : ក្លមមានរាងជារង្វង់ បន្ទាត់ផ្ចិត ១៥ម.ម មាត់ក្លម ៨ម.ម កំពស់ក្លម ១ម.មអណ្តាតភ្លើង មានកំពស់អណ្តាតទីមួយ១៨ម.ម ទីពីរ ១៦ម.ម

ទីបី ១៤ម.ម អណ្តាត ភ្លើងទីបួន១២ម.ម អណ្តាត ភ្លើងនីមួយៗ ប្រវែង ទទឹង ២ម.ម ស្រួចពុះរាងជាអណ្តាតភ្លើង ។

–សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានកងឯកភាពប្រជុំនាញ ភស្តុភារ ភារ(ហ្មត់ចត់) ពាក់លើ កអាវ យោធា ។

១១–សញ្ញាសម្គាល់កងឯកភាពសុខាភិបាល :

រូបភាព : មានរូបសញ្ញាលេខបូក នៅសញ្ញាលេខបូក ត្រង់ទៅលើមានពស់រុំ ...ធ្វើពីលោហធាតុ សញ្ញាលេខបូក ពណ៌ក្រហមពស់ពណ៌ក្រោក ឯក សណ្ឋានប្រយុទ្ធចាក់ដាក់កអាវ ពណ៌មាស ។

ខ្នាត : សញ្ញាលេខបូកនីមួយៗប្រវែង ២៨ម.ម–ទទឹង ១៨ម.ម នៅលើ សញ្ញាលេខបូកត្រង់ទៅលើ មានឆ្នូតបណ្តោយប្រវែង ៦ម.ម ពស់រុំបីជាន ក្បាល ពស់ដាក់ពីលើ កន្ទុយពស់ចុះមកក្រោម ២ម.ម ទទឹងពស់ ២ម.ម ។

–សំរាប់នាយទាហាន នាយទាហានរង និងពលទាហាន កងឯកភាពសុខាភិបាល កងយោធពល ខេមរភូមិន្ទពាក់លើ កអាវ យោធា ។

១២–សញ្ញាកងឯកភាពភូមិសាស្ត្រយោធា :

រូបភាព : មានរូបផែនទីព្រះរាជាណាចក្រកម្ពុជា ពណ៌មាស ក្នុងនោះមាន ទន្លេសាប ទន្លេមេគង្គ នៅលើផែនទីមានរូបកុំប៉ាបញ្ឈរពណ៌ប្រាក់ ផលិតពី លោហធាតុ ឯកសណ្ឋានប្រយុទ្ធចាក់ដាក់ កអាវពណ៌ស ។

ខ្នាត : ទំហំផែនទីមានប្រវែង ៣០ម.ម កំពស់ ២៤ម.ម កំពស់កុំប៉ា ៣០ ម.ម មុំរបស់ចុងកុំប៉ាបើកចេញពីគ្នា ៥០ អង្សារ មុំកុំប៉ាមួយទៅមួយ ២០ ម.ម គល់កុំប៉ាលើលៀនហួសផែនទី ៤ម.ម ចុង ខាងក្រោមលៀនហួស ផែនទី ២ម.ម ។

–សំរាប់នាយទាហាន នាយទាហានរង និងពលទាហាន កងឯកភាពភូមិសាស្ត្រ យោធា ពាក់លើ ក អាវ យោធា ។

១៣—**សញ្ញាសម្គាល់កាំភ្លើងធំ និង ការពារដែនអាកាស** :

**រូបភាព** : មានកាំជ្រួចមួយបញ្ឈរត្រង់ទៅលើ ហើយមានកាណុងកាំភ្លើងធំពីសម័យដើមពីរខ្វែងគ្នាដាក់ពីលើរូបកាំជ្រួច ។ កាណុងខាងឆ្វេង ខ្សែលើខាងស្តាំ ផលិតពីលោហធាតុ ពណ៌មាស កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធ ប៉ាក់ដាក់ កអាវ ពណ៌មាស ។

**ខ្នាត** : កំពស់កាំជ្រួច ៣៤ម.ម កាណុងកាំភ្លើងធំនីមួយៗប្រវែង ៣៤ម.ម មុំកាណុងកាំភ្លើងធំ ខ្វែងគ្នា មានទំហំមុំខាងលើ និងខាងក្រោម ១១០អង្សារ មុំចំហៀង ៧០ អង្សារ ។

–សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានកងកាំភ្លើងធំ កាំជ្រួច និងកងការពារដែន អាកាស ពាក់នៅលើ កអាវ យោធា ។

១៤—**សញ្ញាសម្គាល់រថក្រោះ រថពាសដែក** :

**រូបភាព** : រូបដាវពីរខ្វែងគ្នា នៅចំកណ្តាលមានរូបរថក្រោះ មើលពីមុខ និងក្រចកសេះ ផលិតពីលោហធាតុ ពណ៌មាស កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធប៉ាក់ដាក់ កអាវ ពណ៌មាស ។

**ខ្នាត** : ដាវនីមួយៗប្រវែង ៤២ម.ម(ក្នុងនោះដងដាវ ៨ម.ម )ទទឹងរថក្រោះ ២០ម.ម កំពស់ទាំងកាណុង ១៤ម.ម កំពស់ក្រចកសេះ ១៧ម.ម ចុងក្រចកសេះ ខាងលើពីមួយទៅមួយ ៩ម.ម លើក្រចកសេះ មានស្នាមបោះដែកគោលចំនួន ៥កន្លែង ។

–សំរាប់នាយទាហាន នាយទាហានរង និងពលទាហានរថក្រោះ រថពាសដែក ពាក់លើ កអាវ យោធា ។

១៥—**សញ្ញាសម្គាល់ឯកទេសបញ្ជូនសារ** :

**រូបភាព** : រូបកងចក្រមានស្លាបខាងក្រៅចំនួន ១៦ នៅលើរូបកងចក្រមានរូប សញ្ញារលកធាតុអាកាស មុខឡើងទៅលើ ចុងងាកមកស្តាំ ២៥អង្សារ ផលិតពីលោហធាតុពណ៌មាស កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធ ប៉ាក់ដាក់ កអាវ ពណ៌មាស ។

**ខ្នាត** : បន្ទាត់ផ្ចិតខាងក្រៅ ២៥ម.ម រង្វង់ខាងក្នុង ទីមួយប្រវែង ១៥ម.ម និងទីពីរប្រវែង ១០ម.ម សញ្ញារលកជាតុអាកាស បណ្ដោយប្រវែង ២៦ម.ម ទទឹងតល់សញ្ញា ៦ម.ម ។

-សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានបញ្ជូនសារ ពាក់លើ កអាវយោធា ។

**១៦—សញ្ញាកងវិស្វកម្ម** :

**រូបភាព** : មានរូបវិមានឯករាជ្យបញ្ឈរ ខាងក្រោមមានតាំងភ្លើងបើកគន្លាក់ ប្រាសាទខាងលើមានគន្លាក់ ៧ ជាន់ ផលិតពីលោហធាតុពណ៌មាស កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធ ប៉ាក់ដាក់ កអាវពណ៌មាស ។

**ខ្នាត** : កំពស់ ៣២ម.ម បាតក្រោម ១៦ម.ម តួកណ្ដាល ១២ម.ម គន្លាក់ក្បាច់ទីមួយ បន្ទាប់ពី តួកណ្ដាល ១៤.ម.ម ។

-សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានវិស្វកម្មពាក់នៅលើ កអាវយោធា ។

**១៧—សញ្ញាកងឯកភាពសាលានិងហ្វឹកហ្វឺន** :

**រូបភាព** : មានរូបភាពព្រះខ័នខ្មែរជាមួយស្លាបសត្វមួយ ពណ៌មាស នៅកណ្ដាលមានសៀវភៅ មួយបើកពណ៌ប្រាក់ ផលិតពីលោហធាតុ កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធ ប៉ាក់ដាក់កអាវពណ៌មាស ។

**ខ្នាត** : ព្រះខ័នប្រវែង ៣៤ម.ម ស្លាបសត្វមួយ ៣៥ម.ម កំពស់សៀវភៅ ១០ម.ម បណ្ដោយ ១៥ម.ម ផ្ទត់កណ្ដាលសៀវភៅ ១២ម.ម ។

-សំរាប់នាយទាហាន នាយទាហានរង និង ពលទាហាន កងឯកភាពសាលាគ្រប់ថ្នាក់ ពាក់លើ កអាវ យោធា ។

**១៨—សញ្ញាកងឯកភាពតុលាការយោធា** :

**រូបភាព** : រូបក្បាច់ចម្លាក់អង្គរព័ទ្ធជុំវិញរាងស្វែងក្របី ចំកណ្ដាលជើងពានជញ្ជីង និងសន្លឹក សៀវភៅច្បាប់ផលិតពីលោហធាតុ ពណ៌មាស កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធប៉ាក់ដាក់ កអាវ ពណ៌មាស ។

**ខ្នាត** : បន្ទាត់ផ្ចិតរង្វង់ ក្បាច់ចម្លាក់អក្សរខាងក្រៅ ២៥ម.ម ខាងក្នុង ២០ម.ម ជើងពាន និង ដងជញ្ជីងប្រវែង ១៧ម.ម ដងក្តាងជញ្ជីង ១៣ម.ម សទ្ទីក សៀវភៅ ច្បាប់រៀបរាងកោង ពីលើដងកំពស់ ៥ម.ម ជញ្ជីងបន្តោកចុះ ៦ម.ម ។

–សំរាប់នាយទាហាន នាយទាហានរងនិងពលទាហានតុលាការយោធាគ្រប់ថ្នាក់ ពាក់ លើកអាវយោធា ។

**១៩–សញ្ញាកងឯកភាពអយ្យការយោធា :**

**រូបភាព** : មានរូបជើងពានចំនួនបីថ្នាក់ ទ្រជញ្ជីងផលិតពីលោហធាតុ ពណ៌មាស កំពស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធ ចាក់ដាក់កអាវពណ៌មាស ។

**ខ្នាត** : កំពស់រូបភាព ៣០ម.ម បាតជើងពានខាងក្រោម ១៦ម.ម បាតជើងពានទីពីរប្រវែង ១០ម.ម មាត់ជើងពានទីពីរប្រវែង ២០ម.ម បាតជើងពានទីពីរប្រវែង ១១ម.ម មាត់លើ ប្រវែង ១៥ម.ម បង្គោល ជញ្ជីងរាងកោងចុងមានក្បាច់ប្រវែង ១៧ម.ម ជញ្ជីងបន្តោកចុះ ៦ម.ម កំពស់ជញ្ជីងទីមួយនិងទីពីរ ប្រវែង ១៥ម.ម ជើងពានទី ៣៦ ម.ម ។

–សំរាប់នាយទាហាន នាយទាហានរង និងពលទាហានអយ្យការយោធាពាក់លើកអាវយោធា ។

**២០–សញ្ញាគ្រូនិព និងសិល្បៈ កងយោធពលខេមរភូមិន្ទ :**

**រូបភាព** : មានរូបអក្សរភ្លេងពីសម័យដើម ផលិតចេញពីលោហធាតុ ពណ៌មាស ។

**ខ្នាត** : កំពស់រូបភាព ២៦ម.ម បាតក្រោម ១២ម.ម ទទឹងរូបភាពកណ្តាល ២០ម.ម គំនូស កាត់ខាង លើ១៦ម.ម កំរាស់ ១.៥ម.ម ឯកសណ្ឋានប្រយុទ្ធ ចាក់ដាក់ កអាវពណ៌មាស ។

–សំរាប់នាយទាហាន នាយទាហានរង និងពលទាហានគ្រែទ័ព និង សិល្បៈកងយោធពលខេមរភូមិន្ទ ពាក់លើ កអាវ យោធា ។

**២១—សញ្ញាអាចឯកភាពឆ័ត្រយោធា :**

**សញ្ញាអាចឯកភាពឆ័ត្រយោធមាន ៣ ប្រភេទ :**

**ទី១—រូបភាព** :មានរូបប្រាសាទអង្គរវត្តកំពូលបីនៅចំកណ្ដាលស្លាបសត្វ នៅពីលើ នៅចំកណ្ដាលមានរូបព្រះខ័ន មុខចុះក្រោម នៅកណ្ដាលព្រះខ័នមានរូបតួអក្សរ (ឆ) ខាងក្រោមកណ្ដាល មាន បន្ដោកចុង ស្រួចរាងត្រីកោណ ។ ធ្វើពីលោហធាតុ ប្រាសាទអង្គរ ពណ៌មាស ព្រះខ័ន និង ស្លាប ពណ៌ប្រាក់ រំយោលចុងស្រួច ចំកណ្ដាលចុះក្រោម ពណ៌ក្រហម (ឆ) ពណ៌ខៀវ កំរាល ១.៥ម.ម ឯកសណ្ឋាន ប្រយុទ្ធ ប៉ាក់ដាក់លើហោប៉ៅស្ដាំ ពណ៌ខ្មៅ ។

**ខ្នាត** : កំពស់រូបភាព ៣៧ម.ម ទទឹង ៧០ម.ម ។

–បាតប្រាសាទអង្គរវត្តប្រវែង ៣២ម.ម កំពស់ប្រាសាទ ១៥ម.ម ព្រះខ័ន ប្រវែង ២២ម.ម កំពស់អក្សរ (ឆ) ១០ម.ម កំពស់ស្លាបសត្វ ១៥ ម.ម រំយោលចុះក្រោម ១៤ម.ម សាបសត្វមានពីរជាន់ ជាន់ទីមួយ មាន១១ ស្លាប ជាន់ទីពីរមាន ១០ ស្លាប ។

–សំរាប់នាយទាហាន នាយទាហានរង និង ពលទាហានកងឆ័ត្រយោង ពាក់នៅលើហោប៉ៅខាងស្ដាំ និង ដាក់លើសញ្ញាប័ត្រកងឆ័ត្រយោង (ពាក់បានតែចំពោះយោធិនដែលបានឆ្លងកាត់ការហ្វឹកហាត់ ឆ័ត្រយោងរួច) ។

**ទី ២—រូបភាព** : មានឆ័ត្រយោងស្លាបសត្វ និងខាងក្រោមក្បាច់ភ្ញីផ្កា ទ្រពីខាងក្រោម ផលិតពី លោហធាតុ ឆ័ត្រយោង និងស្លាបសត្វ ពណ៌ទឹកប្រាក់ ផ្កាភ្ញី ពណ៌មាស កំរាស់ ១.៥ម.ម ។

**ខ្នាត** : កំពស់រូបភាព ៤៨ម.ម ទទឹង ៨២ម.ម ។

–កំពស់ឆ័ត្រយោង ៣៥ម.ម ខ្សែឆ័ត្រ ២១ម.ម ឆ័ត្រវែង ១៤ម.ម ទទឹងឆ័ត្រខាងក្រោមចុងឆ័ត្រ និង ខ្សែចន្លោះគល់ស្លាបខាងលើទាំងពីរប្រវែង ៣០ម.ម គល់ស្លាបខាងលើ ទៅចុងស្លាបម្ខាងៗ ប្រវែង ២៥ម.ម ក្បាច់ផ្កាភ្ញីខាងក្រោមរង្វង់ស្នែងក្របី ខាងក្រោមផ្កាមួយមានបន្ទាត់ផ្ចិត ១២ម.ម ផ្កាភ្ញីសងខាងប្រវែង ២២ម.ម ។

**ទី៣–រូបតារា** : រូបភាពនិងខ្នាត ពណ៌មានដូចរូបទីពីរ តែបន្ថែមនៅចំកណ្តាលចំណុចគល់ស្លាប ខាងក្រោមមានគងបីរុំចូលគ្នា ខាងលើពណ៌ក្រហម ខាងឆ្វេងពណ៌លឿង ខាងស្តាំពណ៌ខៀវ រៀវរងមុំចង្ក្រានបន្ទាត់ ផ្ចិតខាងក្រៅ ៨ម.ម ខាងក្នុង ៦ម.ម ។

–សំរាប់នាយទាហាន នាយទាហានរង ជាគ្រូបង្ហាត់ផ្ទះព្រះយោង ពាក់នៅលើហោប៉ៅខាងស្តាំ ដាក់លើ សញ្ញា បំគ្រូផ្ទះយោង ។

**២២–ផ្លាកសញ្ញាកងឯកតាបច្ចេកទេស :**

–ផ្លាកសញ្ញាបច្ចេកទេសរូបមានពីរប្រភេទ គឺប្រភេទទីមួយ សំរាប់នាយទាហាន នាយទាហានរង និងពល ទាហានជំនាញបច្ចេកទេសនៅនាយកដ្ឋានក្រសួង និង ចំណុះទីបញ្ជាការ អគ្គសេនាធិការ និងប្រភេទទីពីរ សំរាប់នាយទាហាន នាយទាហានរង និងពលទាហាន នៅតាមបណ្តាកង ឯកភាពចំណុះ ផ្លាកសញ្ញាទាំងអស់ពាក់នៅលើ កអាវ យោធា ចំពោះឯកសណ្ឋានប្រយុទ្ធ ប៉ាក់ដាក់ កអាវ ពណ៌មាស ។

**សញ្ញាបច្ចេកទេសទី ១ :**

**រូបតារា** : មានរូបកុំប៉ា ស្លាបសត្វ នាវា កាំភ្លើងធំ និងសញ្ញាគ្រឿងចក្រ ផលិតពីលោហធាតុ ពណ៌មាស ឯកសណ្ឋានប្រយុទ្ធប៉ាក់ដាក់ កអាវ ពណ៌មាស ។

**ខ្នាត** : កំពស់កុំប៉ា (កំពស់រូបភាព) ៣ស.ម ចន្លោះចុងកុំប៉ា ម្ខាងទៅម្ខាង ១.៨ស.ម ចុងស្លាប សត្វម្ខាង ២ស.ម ស្លាបសត្វម្ខាងៗមានស្លាប ៩ជាន់ ហើយស្លាបសត្វដាក់នៅចំកណ្តាលកុំប៉ា នៅចន្លោះ កណ្តាលស្លាបសត្វមានរូបនាវាធុនតូច ជាប៊ីបញ្ឈរបណ្តោយកុំប៉ា ដែលមានមុខស្រួច បណ្តោយ ១ស.ម ទទឹងតួចនាវា ០.៣៥ស.ម នៅផ្នែកខាងក្រោយនាវា មានក្បាច់ចតុកោណកែងបួនជាន់ត្រួតលើគ្នា ផ្នែកខាង មុខនាវា មានដាក់រូបកាំភ្លើងធំបណ្តោយ ០៣ស.ម នៅខាងក្រោមស្លាបសត្វ មានរូបសញ្ញាគ្រឿងចក្រខាងក្រោម ២ស.ម បណ្តោយខាងលើ ១.៥ស.ម ទទឹង សញ្ញាគ្រឿងចក្រ ០.៤០ស.ម ។

**សញ្ញាបច្ចេកទេសទី ២ :**

**រូបភាព** : មានរូបកាំភ្លើងពីសម័យបុរាណ ខ្វែងជាមួយកូនសោ (កាំភ្លើងនៅឆ្វេងលើកូនសោនៅស្តាំ)និង មានរូបសញ្ញាគ្រឿងចក្រដាក់លើកាំភ្លើង និងកូនសោផ្នែកខាងក្រោមផលិតពី លោហធាតុ ពណ៌មាស(ឯក សណ្ឋានប្រយុទ្ធ ប៉ាកកអាវពណ៌មាស ។

**ខ្នាត** : កំពស់កាំភ្លើង ៣ស.ម កំពស់កូនសោ ២.៥ស.ម មុំខ្វែងគ្នារវាងកាំភ្លើងនិងកូនសោ១៨ អង្សារ សញ្ញាចក្ររាងកោងឡើងលើ បណ្តោយ ខាងក្រោម ២ស.ម បណ្តោយខាងលើ ១.២ស.ម ទទឹង សញ្ញាគ្រឿងចក្រ ០.៤ស.ម ។

**២៣–ផ្លាកសញ្ញាដាក់កអាវរបស់កងទ័ពពិសេសឆ័ត្រយោង :**

**រូបភាព** : មានរូបកាំភ្លើងពីបុរាណ២ដាក់ខ្វែងគ្នា(ខាងឆ្វេងគងលើខាងស្តាំ) និងរូបឆ័ត្រយោងនៅចន្លោះខ្វែងគ្នារវាងកាំភ្លើងទាំងពីរផ្នែកខាងលើ ផលិតពីលោហធាតុពណ៌មាស ពាក់លើកអាវ យោធា ឯកសណ្ឋានប្រយុទ្ធប៉ាក់លើកអាវ ពណ៌មាស ។

**ខ្នាត** : កំពស់កាំភ្លើងធំមួយ ៣.២ស.ម មុំខ្វែងគ្នា របស់កាំភ្លើង ៨០អង្សារ ។

–កំពស់ឆ័ត្រគីតទាំងខ្សែ ១.៤ស.ម និងខ្សែឆ័ត្រចំនួន៥(ត្អូឆ័ត្រខាងលើ កំពស់ ០.៧ស.ម) ។

**២៤–ផ្លាកសញ្ញាកងឯកភាពដឹកជញ្ជូនគ្រប់ប្រភេទ :**

**រូបភាព** : មានរាងជារង្វង់មូល ដែលជានិមិត្តរូបចង្កូតកប៉ាល់ និងចង្កូតយន្តដាក់ត្រួតពីលើគ្នា ហើយមានកាំចំនួន ៨ ពណ៌មាស នៅចំកណ្តាលមានរូបស្លាបសត្វ ពណ៌ប្រាក់ តំណាងអោយកង ដឹកជញ្ជូន អាកាសចរ ឯកសណ្ឋានប្រយុទ្ធ ប៉ាក់ដាក់ កអាវ ពណ៌មាស ។

**ខ្នាត** : រង្វង់ខាងក្រៅ មានបន្ទាត់ផ្ចិតប្រវែង ២៨ម.ម រង្វង់ខាងក្នុងមានបន្ទាត់ផ្ចិត ២០ម.ម ។

–នៅផ្នែករង្វង់ខាងក្រៅ មានធ្វើជាគន្ទាក់ដូចសញ្ញាគ្រឿងចក្រ ។

-កាំនៃរង្វង់ មាន៨ ចង្កុលទាំង ៨ទិស ។

-ស្លាបសត្វនៅខាងក្នុង ចំកណ្តាលនៃរង្វង់ដាក់គល់ស្លាបមកក្រោម ចុងស្លាបឡើងលើ ។

-ស្លាបមានចំនួន ២ជាន់ ស្លាបនីមួយៗមានស្រទាប់ស្លាប ចំនួន ៦ ។ កំពស់រូបភាពស្លាបប្រវែង ១២ម.ម និងទទឹងប្រវែង ៨ម.ម ។

ផ្លាកសញ្ញានេះ សំរាប់កងឯកភាពដឹកជញ្ជូនគ្រប់ប្រភេទ ដូចជា ដឹកជញ្ជូនជើងគោក នាវាចរ និង អាកាស ចរ ។

**២៥-ផ្លាកសញ្ញាកងជីវពល :**

-ផ្លាកសញ្ញាដេរភ្ជាប់នៅលើដៃអាវស្តាំ ចុះពីថ្នេរស្មា ៥ស.ម មានរាងមូលបន្ទាត់ផ្ចិត ៧ស.ម ស្រទាប់ខាងក្រៅពណ៌មាស ទទឹងស្រទាប់ ៣ម.ម ផ្នែកលើ ១/៤ នៃរង្វង់ពណ៌ខៀវ ហើយសរសេរ អក្សរ (**ព្រះរាជាណាចក្រកម្ពុជា**) កំពស់អក្សរ៥ម.មផ្នែកកណ្តាល ១/២ នៃរង្វង់ពណ៌ក្រហម ហើយមានធ្នូកំពុងយឺតដាក់គ្រាប់ព្រួញ ដើម្បីប្រុងប្រៀបបាញ់ ពណ៌ស កំពស់ធ្នូប្រវែង ៥ម.ម ទទឹងគិតទាំងព្រួញប្រវែង ៥ ស.ម មុខព្រួញត្រូវវត់បញ្ច្រាស់ទិស មានសរសេរអក្សរខាងក្រោមមាន ១/៤ នៃរង្វង់ ពណ៌ខៀវ ហើយសរសេរ អក្សរ (កងជីវពល) កំពស់អក្សរ ៧ម.ម ។ ចំពោះការផលិតធ្វើពីក្រណាត់ អាចបោះពុម្ព ឬ ប៉ាក់ ។

មាត្រា ៧ : **ទង់កងយោធពលខេមរភូមិន្ទ ត្រូវបានកំណត់ដូចខាងក្រោម :**

**១-ទង់កងយោធពលខេមរភូមិន្ទ :**

-យកគំរូទង់ជាតិព្រះរាជាណាចក្រកម្ពុជា មានប្រាសាទកំពូលបី បណ្តោយ ១.៩៥ម. ទទឹង ១.៤៦២៥ម. ដងទង់ ២,៨៥ម. នៅផ្នែកខាងលើជ្រុងខាងដើម មានរូបហនុមានកាន់ព្រះខ័ន ពណ៌មាស កំពស់រូប ហនុមាន ២៥ស.ម ទទឹង ២២ស.ម នៅក្រោមប្រាសាទ សរសេរអក្សរ ពណ៌មាស(កងយោធពលខេមរភូមិន្ទ) កំពស់ អក្សរ១៥ស.ម នៅក្បាលដងទង់ស្រួច ខាងលើឆ្លាក់រូប

មុដមាន ព្រះខ័នទ្រ ពណ៌មាសធ្វើពីលោហធាតុ នៅក្បាលដងទង់មានរំយោលពីរ ពណ៌មាស មួយប្រវែង ១ម មួយទៀតប្រវែង ១.២៥ម ។

**២—ទង់អគ្គសេនាធិការ កងយោធពលខេមរភូមិន្ទ :**

–យកទង់ជាតិព្រះរាជាណាចក្រកម្ពុជា មានប្រាសាទអង្គរវត្តកំពូលបី មានបណ្តោយ ១.៩៥ម ទទឹង ១.៤៦២៥ម. ដងទង់ ២.៨៥ម. ។ នៅជ្រុងខាងលើ ផ្នែកខាងដើមទង់មានសញ្ញាហនុមាន មានទំហំ កំពស់រូបភាព ២៥ម. ទទឹង ២២ស.ម ។

–នៅខាងក្រោមប្រាសាទ លើផ្ទៃពណ៌ខៀវ មានសរសេរអក្សរ ពណ៌មាស (អគ្គសេនាធិការកងយោធពលខេមរភូមិន្ទ)កំពស់អក្សរ ១៥ស.ម ។

–នៅក្បាលដងទង់ស្រួច ខាងលើឆ្លាក់រូបមុដមានព្រះខ័នទ្រ ធ្វើពីលោហធាតុពណ៌មាស នៅក្បាល ដងទង់ មានរំយោល២ ពណ៌មាស មួយប្រវែង ១ម មួយទៀតប្រវែង ១.២៥ម ។

**៣—ទង់ជ័យយោធភូមិភាគ ឬកងធំព ថ្នាក់ឬមហាក់ឬហែល :**

–យកទង់ជាតិព្រះរាជាណាចក្រកម្ពុជា មានប្រាសាទអង្គរវត្តកំពូលបី មានបណ្តោយ ១.៧០ម ទទឹង ១.៣៥ម ដងទង់ ២.៨០ម នៅជ្រុងខាងដើមផ្នែកខាងលើមានរូបសញ្ញាទ័ពជំនាញកំពស់ ២៥ម.ម ទទឹង ២២ស.ម ពណ៌មាស នៅខាងក្រោមប្រាសាទ សរសេរអក្សរ ពណ៌មាស ឈ្មោះកងឯកភាពនីមួយៗ កំពស់ អក្សរ ១៥ស.ម ។ នៅក្បាលដងទង់ស្រួចខាងលើឆ្លាក់រូបមុដ មានព្រះខ័នទ្រ ធ្វើពីលោហធាតុ ពណ៌មាស នៅក្បាលដងទង់មានរំយោល ២ពណ៌មួយប្រវែង១ម មួយទៀតប្រវែង ១.២៥មដោយឡែកអាកាសចរ រូបមុដមានស្លាបសត្វទ្រ និងនាវាចររូបមុដ មានយុថ្កាទ្រពីក្រោម ។ ដោយឡែកអាកាសចរ មានរូបស្លាបសត្វមុដ និង កងនាវាចររូបយុថ្កា ទ្រមុដនៅខាងក្បាលដងទង់ ។

**៤–ទង់ជ័យថ្នាក់កងពលធំ និងថ្នាក់ប្រហាក់ប្រហែល :**

–យកទង់ជាតិព្រះរាជាណាចក្រកម្ពុជា ប្រាសាទអង្គរវត្តកំពូលបី បណ្តោយ ១.៧០ម ទទឹង ១.២៧៥ម ដងទង់ ២.៥៥ម នៅជ្រុងខាងដើម ផ្នែកខាងលើ មានរូបទ័ពជំនាញកំពស់ ២៥ស.ម ទទឹង ២២ស.ម ពណ៌មាស ខាងក្រោម ប្រាសាទសរសេរអក្សរ ពណ៌មាស ឈ្មោះកងឯកភាពនីមួយៗ កំពស់អក្សរ ១៥ស.ម ។ នៅក្បាលដងទង់ស្រួច ខាងលើឆ្លាក់រូបម្កុជាមានព្រះខ័នទ្រ ធ្វើពី លោហធាតុពណ៌មាសនៅកក្បាលដងទង់មានរំយោល ២ ពណ៌មាស មួយ ប្រវែង ១ម មួយទៀតប្រវែង ១.២៥ម ។ ដោយឡែក អាកាសចរ រូបមកុដមានស្លាបសត្វទ្រ និង នាវាចរមានយុថ្កាទ្រពីក្រោម ។

**៥–ទង់ជ័យថ្នាក់កងពលតូច តំបន់ប្រតិបត្តិការសឹក ទ័រសេនាធំ និងថ្នាក់ ប្រហាក់ប្រហែល :**

–យកទង់ជាតិព្រះរាជាណាចក្រកម្ពុជា មានប្រាសាទកំពូលបី មានបណ្តោយ ១.៦០ម ទទឹង ១.២០ម ដងទង់ ២.៤០ម ។ នៅជ្រុងខាងដើមផ្នែកខាងលើ មានរូបសញ្ញាទ័ពជំនាញ ពណ៌មាសមានកំពស់ ដូចខាងលើ ខាងក្រោម ប្រាសាទ អង្គរវត្តសរសេរអក្សរពណ៌មាស ឈ្មោះកងឯកភាពនិមួយៗ (កំពស់អក្សរ ១៥ស.ម) ។ នៅក្បាលដងទង់ស្រួច ខាងលើឆ្លាក់រូបព្រះខ័ន ធ្វើពីលោហធាតុ ពណ៌មាស នៅក្បាល ដងទង់មានរំយោល២ ពណ៌មាស ប្រវែង ១ម មួយទៀត ប្រវែង ១.២៥ម ។ ដោយឡែកអាកាសចរ រូបមកុដមានស្លាបសត្វទ្រពីក្រោមមកុដ និងនាវាចរ មានរូប យុថ្កាទ្រពីក្រោម ។

**មាត្រា ៨** : ត្រូវបានកំណត់អំពីរបៀបប្រើប្រាស់ និង ពាក់ឯកសណ្ឋាន ផ្លាកនានា នៃកង យោធពលខេមរភូមិន្ទដូចខាងក្រោមនេះ ÷

ការស្លៀកពាក់ឯកសណ្ឋាន គឺជាច្បាប់របស់កងយោធពលខេមរភូមិន្ទ ដែល នាយទាហាន នាយទាហានរង និង ពលទាហានគ្រប់រូប ត្រូវអនុវត្តន៍យ៉ាង ម៉ឺងម៉ាត់បំផុតមិនអាចខ្វះបានឡើយ សំដៅធ្វើអោយយោធិនគ្រប់រូបទូទាំង កងយោធពលខេមរភូមិន្ទ បានឯកភាពគ្នា ។ ហើយការស្លៀកពាក់ឯក

សណ្ឋានត្រូវអនុវត្តន៍អោយត្រឹមត្រូវតាមការកំណត់ នៃអនុក្រឹត្យនេះ មិនអនុញ្ញាតិអោយយោធិនណាម្នាក់ ស្លៀកពាក់ខុសពីការកំណត់ឡើយ ហើយការស្លៀកពាក់ឯកសណ្ឋាន ត្រូវតែពាក់សក្តិ តាមឋានន្តរសក្តិរបស់ខ្លួនព្រមទាំងផ្លាកសញ្ញាផ្សេងៗ ដែលកងយោធពលខេមរភូមិន្ទ បានកំណត់ ។

**ការប្រើប្រាស់ និងពាក់ឯកសណ្ឋាន ផ្លាកសញ្ញានានា :**

**១–ឯកសណ្ឋានធំលេខ ១ (អាវកុដស )**

–ឯកសណ្ឋានធំលេខ ១ សំរាប់ដាក់ក្នុងពិធី ក្នុងព្រះបរមរាជវាំង និងព្រះរាជពិធីដូចជា(ច្រត់ព្រះ នង្គ័ល អុំទូក បុណ្យឯករាជ្យជាតិ ។ល។

–ស្លៀកពាក់ឯកសណ្ឋានធំ អាវកុដស ខោពណ៌ក្រមៅ ឆ្នូតក្រហម មួកកាស្កេតខ្មៅ មានរូបព្រះសង្ហារ ស្បែកជើងឃ្លុបស្បែក កខ្លីពណ៌ខ្មៅ ស្រោមជើងខ្មៅពាក់សក្តិលើស្មា ដែលមានផ្ទៃហុងសក្តិក្រណាត់កាំម្ពី ពណ៌មាស ពាក់ខ្សែរិយោលលើស្មាស្តាំ កន្ទុយខ្សែថ្នាក់ឡេវអាវទី២ និង ពាក់គ្រឿងឥស្សរិយយសនៅខាងឆ្វេង (បើមាន)ហើយស្រោមដៃតាមពិធីការកំណត់ ។ ចំពោះផ្លាកឈ្មោះ រូបហនុមាន និងសញ្ញាប្រភេទទ័ពនៅកអាវ ឬ សញ្ញាផ្សេងៗទៀតមិនត្រូវពាក់ជាមួយឯកសណ្ឋានធំ លេខ ១ នេះឡើយ ។

–ចំពោះកងនាវាចរ និងអាកាសចរ ត្រូវពាក់ឯកសណ្ឋានធំលេខ ១ របស់ខ្លួនរបៀបស្លៀកពាក់និង ពាក់សំភារះរួមផ្សំដូចទ័ពជើងគោកដែរ ។

**២–ឯកសណ្ឋានធំលេខ ២ (អាវទ័រី)**

–ឯកសណ្ឋានធំលេខ២នេះ ពាក់សំរាប់ចូលរួមពិធីការជាតិ និង អន្តរជាតិធំ ៗ (តាមការកំណត់របស់ពិធីការ) ព្រមទាំងការចេញទៅបំពេញបេសកម្ម ក្រៅប្រទេស ។

–ស្លៀកពាក់ឯកសណ្ឋានធំលេខ ២ ពេលថ្ងៃពាក់អាវស៊ីមី ពណ៌កាគី ពេលយប់និងពិធីបុណ្យសពអាវស៊ីមីពណ៌ស ក្រវាត់កពណ៌ខ្មៅ ខោជើង វែងពណ៌កាគីមួកកាស្កេតពណ៌កាគី មានរូបព្រះសង្ហារ ស្បែកជើងកខ្លី ពណ៌ខ្មៅ ស្រោម

ជើង ពណ៌ខ្មៅ ពាក់សក្តិស្មា ផ្តៃហ្វុងពណ៌ខ្មៅ ក្បាលស្រួច ពាក់ខ្សែរំដោយលើស្មាស្តាំ កន្ទុយខ្សែពាក់ខ្សៀវអាវទី១ ពាក់សញ្ញានៅ កអាវ ពាក់ផ្លាកឈ្មោះលើ ហោប៉ៅអាវស្តាំ បន្ទោករូបហនុមានលើហោប៉ៅស្តាំ ពាក់ស្រោមដៃ តាមពិធីការកំណត់ និង គ្រឿងឥស្សរិយយសនៅខាងឆ្វេង (លក្ខណៈចាំបាច់ គួរពាក់មេដៃ និង លក្ខណៈធម្មតា ពាក់ក្បាលមេដៃ) ។ ចំពោះការចេញទៅបំពេញបេសក កម្មក្រៅប្រទេស មិនបានពាក់ខ្សែរំយោលឡើយ ។

– ចំពោះកងនាវាចរ និង អាកាសចរ ត្រូវស្លៀកពាក់ឯកសណ្ឋានធំលេខ២របស់ខ្លួន និង ពាក់គ្រឿង រួមផ្សំផ្សេងទៀត ព្រមទាំងរបៀបពាក់ដូចទ័ពជើងគោកដែរ ។ តែកងអាកាសចរឆ័ត្រយោង ត្រូវពាក់សញ្ញារបស់ខ្លួនលើផ្លាកឈ្មោះថែមទៀត។ ការចេញទៅក្រៅប្រទេសមិនបានពាក់ខ្សែរំយោលឡើយ ។ ចំពោះនៅដៃអាវ មិនបានពាក់ផ្លាកកងយោធពលខេមរភូមិន្ទ និង ផ្លាកអ្វីទៀតឡើយ ។

**៣–ឯកសណ្ឋានលេខ ៣ (សាហារីយ៉េន)**

– ឯកសណ្ឋាននេះពាក់សំរាប់ចូលរួមក្នុងពិធីជាតិ អន្តរជាតិដែល មានលក្ខណៈធម្មតា និង ពិធីការយោធាផ្សេងៗ ដូចជាទទួលភ្ញៀវជាតិ អន្តរជាតិ ពិធីបិទវគ្គបើកវគ្គ ។ ល ។

**–ការស្លៀកពាក់** : ពាក់អាវសាហារីយ៉ែន នៅដៃអាវស្តាំ មានផ្លាកកងយោធពលខេមរភូមិន្ទ ខោជើងវែង ពណ៌គ្រែអ៊ី មួកកាស្កេត ពណ៌កាគីមានរូបព្រះសង្ហារ ស្បែកជើងស្បែក កខ្ចីពណ៌ខ្មៅ ពាក់សញ្ញាក ពាក់សក្តិស្មាដែលមានផ្តៃហ្វុងសក្តិពណ៌ខ្មៅក្បាលស្រួច ពាក់ផ្លាកឈ្មោះ សញ្ញាហនុមាន និងក្បាលមេដៃ (បើមាន) ។

– ចំពោះកងនាវាចរ និងអាកាសចរ ត្រូវស្លៀកពាក់ឯកសណ្ឋានលេខ៣របស់ខ្លួន ហើយពាក់គ្រឿងរួមផ្សំផ្សេងទៀត និងរបៀបប្រើប្រាស់ដូចទ័ពជើងគោក តែកងអាកាសចរឆ័ត្រយោង ឬ កងឯកភាពដែលមានសញ្ញាពាក់លើហោប៉ៅស្តាំ លើផ្លាកឈ្មោះត្រូវពាក់ថែមទៀត ។

**៤—ឯកសណ្ឋានលេខ ៤ (ឯកសណ្ឋានការងារ )**

–ឯកសណ្ឋាននេះសំរាប់ពាក់ធ្វើការងារធម្មតាក្នុងការិយាល័យ ឬក្នុងបន្ទាយ និង ទំនាក់ទំនងការងារធម្មតា ។

–**ការស្លៀកពាក់** : ពាក់អាវដៃខ្លី ពណ៌កាគី នៅដៃអាវស្តាំដាក់ផ្លាក កងយោធពលខេមរភូមិន្ទ និង នៅដៃអាវឆ្វេង ពាក់ផ្លាកកងឯកភាព(បើមាន) ខោជើងវែងពណ៌គ្រែអ៊ី ខ្សែក្រវាត់តូច ពណ៌គ្រែអ៊ី មួកបោនេ ពណ៌គ្រែអ៊ី មានរូបព្រះសង្ហារនៅខាងផ្នែកខាងស្តាំ ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅ និង ស្រោមជើងខ្មៅ ពាក់សញ្ញាប្រភេទទ័ពនៅកអាវ ផ្លាកឈ្មោះលើហោប៉ៅស្តាំ សញ្ញាហានុមានពាក់នៅទ្បេវហោប៉ៅស្តាំ សក្តិស្មាដែលមានហ្វុង សក្តិខ្មៅក្បាលស្រួច និងពាក់ក្បាលមេដៃ (បើមាន)អាវជានិច្ចត្រូវដាក់ក្នុងខោ ។

–ចំពោះកងនាវាចរ និងអាកាសចរត្រូវស្លៀកពាក់ឯកសណ្ឋាន ការងារតាមការកំណត់ខាងលើ ហើយពាក់គ្រឿងរូបផ្សំផ្សេងទៀត និងរបៀបប្រើប្រាស់ ដូចទ័ពជើងគោក តែកងអាកាសចរ និងបណ្តាកងឯកភាព ដែលមានសញ្ញាលើហោប៉ៅស្តាំ លើផ្លាកឈ្មោះត្រូវពាក់ថែមទៀត ។

**៥—ឯកសណ្ឋានលេខ៥(ឯកសណ្ឋានប្រយុទ្ធ)**

–ឯកសណ្ឋានប្រយុទ្ធនេះ ពាក់សំរាប់ចេញប្រតិបត្តិការ ឬបេសកកម្មក្រៅបន្ទាយ ចំពោះនៅក្នុងបន្ទាយអាចពាក់បាន តែត្រូវមានការកំណត់ពីមេបញ្ជាការ ហើយអោយបានឯកភាពគ្នាទូទាំងកងឯកភាព ។

–**ការស្លៀកពាក់** : ពាក់អាវដៃវែង ហោប៉ៅបួន អាចមូរដៃបាន តែត្រូវឯកភាពគ្នា(បើសិនជាមូរត្រូវមូរទាំងអស់គ្នា) នៅដើមដៃអាវស្តាំ ដាក់ផ្លាកកងយោធពលខេមរភូមិន្ទ និង ដើមដៃអាវ ឆ្វេងដាក់ផ្លាកកងឯកភាព (បើមាន) ខោជើងវែងមានហោប៉ៅ៦ ជើងខោចងខ្សែ ពាក់មួកហ៊្សកកី មានរូបព្រះសង្ហារ ឬ ពាក់ប៉េរ៉េដាក់រូបព្រះសង្ហារស្តាំ ទាញបញ្ឆិតមកឆ្វេង នៅពេលចេញប្រតិបត្តិការសឹក អាចពាក់មួកដែក (ចំពោះការពាក់មួកគ្រប់ប្រភេទ ត្រូវអនុវត្តតាមការកំណត់របស់កងឯកភាពនីមួយៗ បើសិនពាក់មួយណា ត្រូវពាក់មួយនេះ

អោយបានឯកត្តាទាំងអស់ ហើយហាមការស្លៀកពាក់ដោយគ្មានមួក ពាក់សក្តិប្រយុទ្ធនៅកអាវឆ្វេង នៅកអាវស្តាំពាក់ផ្លាកសញ្ញាប្រភេទទ័ព ឬ ជំនាញនៅកអាវ (អាចប៉ាក់ដេរភ្ជាប់កអាវពណ៌មាស) ផ្លាកឈ្មោះត្រូវដេរភ្ជាប់អាវលើហោប៉ៅស្តាំ អក្សរពណ៌ខ្មៅ ពាក់កន្សែងរុំក អាចមិនពាក់បានតាមការកំណត់របស់កងឯកភាព ពាក់សាំងទៀរុង (ខ្សែក្រវ៉ាត់ធំ) និងពាក់ស្បែកជើងកវែង ពណ៌ខ្មៅ ឬស្បែកជើង ម៉ៃហ្វុកកវែង ។

–ចំពោះកងអាកាសចរ និង នាវាចរពាក់ឯកសណ្ឋានប្រយុទ្ធរបស់ខ្លួន ហើយពាក់គ្រឿងរួមផ្សំ និងរបៀបប្រើប្រាស់ដូចទ័ពជើងគោក ។ តែងកងអាកាសចរ និងបណ្តាកងឯកភាពដែលមានសញ្ញា លើហោប៉ៅស្តាំ លើផ្លាកឈ្មោះត្រូវប៉ាក់ដាក់ភ្ជាប់អាវរូបសញ្ញាពណ៌មាស ។

**៦–ឯកសណ្ឋានបច្ចេកទេសជំនាញ :**

–ការស្លៀកពាក់ឯកសណ្ឋានបច្ចេកទេសជំនាញដែលបានកំណត់ខាងលើចំពោះបណ្តាកងឯកភាពដែលមានឯកសណ្ឋាននេះ ត្រូវពាក់នៅពេលធ្វើការបច្ចេកទេសជាមួយគ្រឿងចក្រ និង ឧបករណ៍បច្ចេកទេសពេលចប់ត្រូវផ្លាស់ប្តូរវិញ មិនបានពាក់ឯកសណ្ឋាននេះ ដើរចេញក្រៅកងឯកភាព ឬ ក្រៅម៉ោងធ្វើការងារបច្ចេកទេសឡើយ លើកលែងតែកងជីវពល អ្នកបើកបរយន្តហោះ ។ ហើយឯកសណ្ឋាននេះមិនចាំបាច់ពាក់សក្តិសញ្ញាផ្សេងៗ របស់យោធពលខេមរភូមិន្ទទេ ។ តែអ្នកបើកបរយន្តហោះត្រូវដាក់រាល់សញ្ញាដែលមាន (ប៉ាក់ភ្ជាប់ និង សក្តិ) ។

៧– ចំពោះទង់កងយោធពលខេមរភូមិន្ទ គ្រប់បណ្តាថ្នាក់ ត្រូវរក្សាទុកកន្លែងដែលមានសុវត្ថិភាពថ្លៃថ្នូរ និង ការពារយ៉ាងហ្មត់ចត់បំផុត ។ ក្នុងរយៈពេលមួយឆមាស ត្រូវប្រាព្ធពិធីសច្ចាប្រណិធាន ចំពោះមុខទង់របស់ខ្លួនម្តង ។ ពេលយកចេញមកក្រៅ ត្រូវធ្វើអោយបានត្រឹមត្រូវតាមភូមិបទយោធា ។

–នាយទាហាន នាយទាហានរង និង ពលទាហានទូទាំងកងយោធពលខេមរភូមិន្ទ ត្រូវស្លៀកឯកសណ្ឋានតាមការកំណត់ខាងលើ ក្នុងអនុក្រឹត្យនេះ ។ ចំពោះ បុគ្គលណាមួយដែលមិនបានស្លៀកពាក់អោយបានគ្រប់គ្រាន់តាមការ

កំណត់នេះ ត្រូវចាត់ទុកជាការល្មើសនិងវិន័យរបស់កងយោធពលខេមរភូមិន្ទ ។

–ចំពោះការផលិត ត្រូវធ្វើតាមការកំណត់របស់អនុក្រឹត្យនេះ និងមានគុណភាពខ្ពស់ ។

–ក្នុងករណីមានការជំនួយពីបណ្តាលប្រទេសជាមិត្ត អំពីឯកសណ្ឋាន ឬ យោធបរិក្ខារផ្សេងៗ ហើយខុសពីការកំណត់នេះ អាចប្រើប្រាស់បាន លុះត្រាតែមានការអនុញ្ញាតជាផ្លូវការពីក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃកងយោធពលខេមរភូមិន្ទ ។

មាត្រា ៩ : រាល់អនុក្រឹត្យណា ឬ សេចក្តីសំរេច ដែលផ្ទុយពីអនុក្រឹត្យ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១០ : សហរដ្ឋមន្ត្រី ទីស្តីការរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការ និងអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តន៍អនុក្រឹត្យនេះ ។

មាត្រា ១១ : អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថ និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រហស្តលេខានិងត្រា** | **ហត្ថលេខា និងត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៧

**អនុក្រឹត្យលេខ ០៨ អនក្រ.បក**

**ស្តីពី**

**ការដាក់ផ្សាយបំណុលរតនាគារ**

* * *

**រាជរដ្ឋាភិបាល**

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយក រដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ រៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១០៩៤ ៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស រកត ១០៩៤ ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំងសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស រកម ០៩៩៥ ០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញរាជក្រមលេខ នស រកត ០១៩៦ ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល លេខ ៨៦ សសរ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៩៥ ស្តីពីពីការបង្កើតគណៈកម្មការអន្តរក្រសួងទទួលបន្ទុកការរៀបចំ និង ការផ្សព្វផ្សាយប័ណ្ណរតនាគារ
- តាមសំណើរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា និង អភិវឌ្ឍន៍ និង ជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- គណៈរដ្ឋមន្ត្រីយល់ព្រមផង

## សំរេច

**មាត្រា ១** : បោះផ្សាយជាសាធារណៈនូវប័ណ្ណរតនាគារ សំរាប់ជំនួសអោយការខ្ចីប្រាក់រៀល ដែលមានរយៈពេលកំណត់ស្មើ ឬ តិចជាង ២ ឆ្នាំ ។

**មាត្រា ២** : ចំនួនទឹកប្រាក់នៃការលក់ប័ណ្ណរតនាគារដែលដាក់អោយចរចរ ត្រូវបញ្ចូលទៅក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

**មាត្រា ៣** : ប័ណ្ណរតនាគារត្រូវបានបោះផ្សាយតាមរូបភាពពីគឺ :

- ប័ណ្ណរតនាគារជារូបមន្ត
- ប័ណ្ណរតនាគារគណនីចរន្ត

**មាត្រា ៤** : ប័ណ្ណរតនាគារជារូបមន្ត គឺជាសិទ្ធិរូបីនៃឥណទេយ្យលើរតនាគារជាតិ ។ ប័ណ្ណនេះអាចផ្ទេរ លក់ បញ្ចាំ ឬ អោយខ្ចីទៅម្ចាស់ថ្មីប្រសិនជាប័ណ្ណគ្មាននាមចារឹក ឬ មួយដោយចារខ្នងប្រសិនជាប័ណ្ណមាននាមចារឹក ។

**មាត្រា ៥** : ប័ណ្ណរតនាគារគណនីចរន្ត គឺជាសិទ្ធិអរូបីនៃឥណទេយ្យលើរតនាគារជាតិ ។ ប័ណ្ណនេះអាចផ្ទេរឈ្មោះ អាចលក់ អាចដាក់ជាការធានា ឬ អាចអោយខ្ចីដោយការបង្វែរពីគណនីមួយទៅគណនីផ្សេងទៀត ។

**មាត្រា ៦** : ប័ណ្ណរតនាគារជារូបមន្ត គឺសំរាប់លក់ (ចុះឈ្មោះ) អោយឯកជន និង សហគ្រាស ឬ អង្គភាពផ្សេងៗទៀត ដែលមិនមែនជាអង្គភាពហិរញ្ញវត្ថុ ។ អត្រាការប្រាក់នៃការដាក់ផ្សាយ ត្រូវបានសំរេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយអត្រាការប្រាក់នេះអាចមិនប្រែប្រួល និង ផ្តល់ការប្រាក់មុន ឬ ការប្រាក់កើនឡើង ។

**មាត្រា ៧** : ប័ណ្ណរតនាគារជារូបមន្ត អាចទូទាត់សងវិញតាមតំលៃដែលបានកំណត់លើសន្លឹកប័ណ្ណដោយរតនាគារជាតិ ឬ ស្ថាប័នដែលមានការប្រគល់សិទ្ធិពីរតនាគារជាតិ ដោយគិតពីថ្ងៃផុតកំណត់រហូតដល់ ៣០ ឆ្នាំ ។

**មាត្រា ៨** : ប័ណ្ណរតនាគារគណនីចរន្ត សំរាប់ការចុះឈ្មោះនៃធនាគារ នៃក្រុមហ៊ុនធានារ៉ាប់រង និង នៃអន្តរការីហិរញ្ញវត្ថុផ្សេងៗ ។

អត្រាការប្រាក់នៃការដាក់ផ្សាយ ត្រូវបានសំរេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ តាមរយៈការដេញថ្លៃរបស់អ្នកចុះឈ្មោះទិញ ។

មាត្រា ៩ : រូបវន្តបុគ្គល និតិបុគ្គល ឬ អង្គភាពផ្សេងៗទៀតដែលមិនមែនជាអង្គភាពហិរញ្ញវត្ថុ អាចចុះឈ្មោះទិញប័ណ្ណរតនាគារតណនីចរន្ត តាមរយៈធនាគាររបស់ខ្លួន ។

មាត្រា ១០ : ធនាគារទាំងឡាយ អាចបង់ចូលក្នុងគណនីចរន្តនៃប័ណ្ណរតនាគាររបស់ខ្លួន នូវប័ណ្ណ រតនាគារជារូបមន្តមិនទាន់ផុតកាលកំណត់ ដែលបានរក្សាទុកបន្ទាប់ពីការទិញទិញ ឬបន្ទាប់ជាក់ធានាពីអ្នកទិញទៀតទាត់ក្រៅពីចុះឈ្មោះទិញធម្មតា ។

មាត្រា ១១ : រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកគ្រប់គ្រងការដាក់ផ្សាយប័ណ្ណរតនាគារ ទោះបីស្ថិតក្នុងទ្រង់ទ្រាយណាក៏ដោយ ។ ផ្នែកសំណើរបស់គណៈកម្មការចំរុះអន្តរក្រសួង ទទួលបន្ទុករៀបចំដាក់ផ្សាយប័ណ្ណ រតនាគាររដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវកំណត់អោយប្រកាសនូវ បរិមាណដែលត្រូវដាក់ផ្សាយរយៈកាលវសាន្ត អត្រាការប្រាក់ ឬ ការដាក់អោយដេញថ្លៃ លក្ខខណ្ឌនៃការចុះឈ្មោះទិញ និង លក្ខខណ្ឌនៃការទូទាត់សងក៏ដូចជាលក្ខខណ្ឌពិសេសផ្សេងៗ ទៀត ។

មាត្រា ១២ : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសិទ្ធិក្នុងការប្តូរ ឬ ប្រមូលទិញឡើងវិញពីលើទីផ្សារនូវប័ណ្ណរតនាគារ ដែលបានដាក់ផ្សាយហើយ ។ ការប្តូរ និង ការទិញមកវិញទាំងនេះត្រូវបានធ្វើដោយឥតបង្ខំ ចំពោះអ្នកដែលបានទិញប័ណ្ណ ។ ប័ណ្ណរតនា គារដែលបានប្តូរ ឬ បានទិញជាថ្មីឡើងវិញ ត្រូវបានលុបចោលភ្លាមនូវប័ណ្ណចាស់ដែលបានទូទាត់រួច ។ ការប្រាក់ដែលជាកាតព្វកិច្ចរបស់រដ្ឋលើប័ណ្ណប្តូរ ឬ ទិញមកវិញត្រូវបានទូទាត់តាមចំនួនប្រាក់ដែលបានជំពាក់រហូតដល់ថ្ងៃកំណត់ សង ឬ ថ្ងៃបានទិញមកវិញ ។

មាត្រា ១៣ : រាល់ការសំរេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការដាក់ផ្សាយនឹងការគ្រប់គ្រងប័ណ្ណរតនាគារ ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ១៤** : ធនាគារជាតិនៃកម្ពុជា ត្រូវទទួលបន្ទុកគ្រប់គ្រងគណនីចរន្តនៃប័ណ្ណរតនាគារ និង រៀបចំចាត់ចែងរាល់ពិធីដេញថ្លៃ ព្រមទាំងទទួលខុសត្រូវលើកិច្ចការនេះ ដើម្បីអោយដំណើរការបានល្អ ។

**មាត្រា ១៥** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា និង ក្រសួងស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | | |
|---|---|---|
| បានបង្គំទូលថ្វាយនិងជំរាបជូន | **នាយករដ្ឋមន្ត្រីទី១** | **នាយករដ្ឋមន្ត្រីទី២** |
| សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២ | **ព្រះហស្តលេខានិងត្រា** | **ហត្ថលេខានិងត្រា** |
| ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីតិសម្បទា | **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

និង អភិវឌ្ឍន៍

និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៧

## អនុក្រឹត្យលេខ ០៥ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា